ធម្ម៌សន្ទិយា

ទស្សនាវិជ្ជ៍ ជ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៦ ខែ មិថុនា

ព.ស. ២៥០៣ គ.ស. ១៩៦៥

- ភ្នំពេញ -

អង្គុយ

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បោះពុម្ពរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្ស

មាតិកា

ផ្នែកសាសនា	*ទំព័រ*
១– អំពីតំហរវត្ត ព្រះមុនីកោសល ស្ងួ ហាយ រៀបរៀង	៥៤៦
២– ប្រស្នាព្រះបាទបាយ៉ាសាកដញ្ជ: លោក ម្ហ ថ្ងូ រៀបរៀង	៥៥៨
ផ្នែកអក្សរសាស្ត្រ	
៣ - វចនានុក្រម សំស្ក្រិត-ខ្មែរ ព្រះមហា ជ៉ាង–ទាត់ រៀបរៀង (ត) . . .	៥៦៤
៤ – វត្តព្រះពុទ្ធសាសនាខ្មែរ នៅខេត្តមាត់ជ្រូកកម្ពុជាក្រោម លោក ឆ. ឌាម រៀបរៀង .	៥៦៧
៥ - រឿងសាមកុក អ្នកឧកញ៉ាវ៉ាប្រុលជដសេនា ទូ - ពន ប្រែរៀបរៀង(ត) . . .	៥៨៧
៦– ព្រះរាជនិពន្ធកាមណ្ដើ លោក ឆ. ឌាម ស្រាវជ្រាវ (ត)	៦០៣
៧– ដំណើរទៅខេត្តកំពង់ស្ទឹងមានជ័យ លោក ហ៊ីន សារ៉ី រៀបរៀង	៦២១
៨– លទ្ធផលនៃការប្រឡងប្រជែងចំនៀមទម្លាប់ខ្មែរ ក្នុងឆមាសទី ១ ឆ្នាំ ១៩៦៥ . .	៦៣៤
៩ ចំនៀមអ្នកស្រុកប៉ៃលិន លោក លី -ឌាមតេង រៀបរៀង	៦៣៦
១០– វិវត្តន៍នៃអក្សរខ្មែរ លោក ឆ. ឌាម រៀបរៀង (ត)	៦៤៣
ផ្នែកកំណត់ទិដ្ឋប្រវត្តិការណ៍	
១១– ព្រះរាជដំណើរ សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឆរាជថ្នាក់ទី២ គណៈធម្មយុត្តិកនិកាយ	៦៤៩
១២ ដំណឹងពីក្រសួងធម្មការ	៦៥៨

មួយឆ្នាំមាន ១២ លេខ តម្លៃ ២៣០០០ ។

ដ្ឋកសាសនា

ពាក្យយាតមិនឲ្យ	ធ្វើការអាក្រក់
ដាការណាបក,	ឲ្យធ្វើល្អទៅ,
ឲ្យដុសខាតចិត្ត	កុំឲ្យហ្មងសៅ
បីនេះណោកហៅ	ពុទ្ធសាសនា ។

ប.ព.

អំពីគិហិវត្ត

(ត)

ព្រះមុនីកោសល សូរ - ហាយ

អធិបតីរងនៃក្រុមដំនុំព្រះត្រៃបិដក រៀបរៀង

កិច្ចវត្ត នៃស្វាមីភរិយា

ស្វាមីនិងភរិយាជាគូស្រករយ៉ាងជិតស្និទ្ធបំផុត ដែលមាតាបិតាទាំងពីរទាងបានរៀបចំទុកជាក់តាមប្រពៃណីនិយម ។ បុត្តធីតា កាលបើមានវ័យចំរើនឡើងដល់ថ្នាក់ថាជាមនុស្សកម្លោះក្រមុំពេញបរិបូណិហើយ ផុតអំពីការសិក្សាហើយ មាតាបិតាតែងមានចិត្តត្រិះរិះចំពោះអនាគតនៃជីវិតកូនកម្លោះក្រមុំរបស់ខ្លួន ក្នុងការផ្សំផ្គុំឲ្យមានស្វាមីតាមប្រពៃណី សមគួរដល់វង្សត្រកូលរបស់ខ្លួន ។

កូនប្រុសរបស់មាតាបិតាក្នុងសម័យមុន កាលបើមានវ័យចំរើនគួរដល់ការសិក្សាហើយ មាតាបិតាតែងនាំយកទៅទុកជាក់ឲ្យនៅឯវត្តអាវាម

ដើម្បីឲ្យរៀនអក្សរសាស្ត្រជាតិនិងធម៌អាថិ ល្មមចេះដឹងគួរសមហើយ ក៏ឲ្យបួសជាសាមណេរ លុះដល់អាយុគ្រប់ ៦០ បរិបូណ៌ក៏ឲ្យបំពេញឧប-សម្បទាជាភិក្ខុទៀត នេះជាប្រពៃណីរបស់ជនជាតិខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ។ កុលបុត្តដែលបានទទួលបព្វជ្ជាជាសាមណេរជាភិក្ខុ ខ្លះបួសបានតិចវស្សា ខ្លះបានច្រើនវស្សា ខ្លះក៏បួសរហូតទាល់តែអនិច្ចធម្មក្នុងភេទផ្ទុស ។ បព្វជិតដែលចាកសិក្ខាបទមកជាគ្រហស្ថហើយ មាតា-បិតាតែងណែនាំក្នុងការស្តីដណ្តឹងកូនស្រីគេ ដើម្បីឲ្យជាភរិយារបស់កូនខ្លួន ។ ទំនៀមជនជាតិខ្មែរយើងច្រើនតែឲ្យកូនប្រុសបួសបំពេញកិច្ចក្នុងព្រះពុទ្ធសាសនារួចហើយ ទើបទុកជាក់ឲ្យមានភរិយា ។

ប្រពៃណីរបស់យើងដែលឲ្យកូនបួសជាមុន ទើបផ្សំផ្ទុំឲ្យមានភរិយាជាខាងក្រោយនេះ ដោយហេតុ :

១) ដើម្បីឲ្យកូនទទួលការអប់រំចិត្តឲ្យបានល្អ

២) ដើម្បីឲ្យយើញប្រាកដថាជាអ្នកកាន់ព្រះពុទ្ធសាសនា

៣) ដើម្បីផលានិសង្សផ្ទុសរបស់កូនផងរបស់មាតាបិតាផង ។

ប្រពៃណីដែលឲ្យកូនបួសនេះ ដោយតិតយើញថា កាលបើកូនបានបួសបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា បានទទួលការអប់រំក្នុងផ្លូវសីលធម៌ហើយ រមែងទៅជាមនុស្សល្អ គួរដល់ការគ្រប់គ្រងគ្រួសារបានសេចក្តីសុខចម្រើនជាប្រាកដ ។ ការបួសនេះ ជាកិច្ចកសាងមនុស្សឲ្យចុះរបៀបល្អក្នុងផ្លូវសីលធម៌ ។

ប្រពៃណីដែលឲ្យកូនបួសរបស់ជនជាតិវ្នែរយើងឥឡូវនេះ ចេះតែ
សាបរលាបម្ពងបន្ពិច ។ ឆ្លូតឲ្យស្តាយណាសដែរ ដោយហេតុតែកាល
សម័យចេះតែជូរផ្ទាស់ប្រពៃណីរបស់មនុស្ស នាំឲ្យប្រែប្រួលដែលមិនអាច
នឹងទប់ទល់ការកំងបានឡើយ ។

បន្ទាប់តទៅនេះ សូមសំដែងអំពីកិច្ចវត្តរវាងស្វាមីនិងករិយា ជូច
សេចក្តីរៀបរាប់ព្រមទាំងអធិប្បាយតទៅ

ស្វាមីកម្បីឧំនុកាបំរុងករិយាដោយហេតុ ៥ យ៉ាង

១ – សម្មានតា ការរាប់អានដ៏ស្មោះស្មើ

២ – អរិមានតា មិនមើលងាយ

៣ – អនតិចរិយា មិនប្រព្រឹត្តក្បត់ចិត្ត

៤ – ឥស្សរិយភេស្សត្តៈ ប្រគល់តាពជាធំក្នុងផ្ទះ

៥ – អលង្ការានុប្បទានៈ ផ្តល់គ្រឿងអលង្ការ ។

១ – សម្មានតា ការរាប់អានដ៏ស្មោះស្មើ

ពាក្យថា ការរាប់អានដ៏ស្មោះស្មើ បានដល់ការទំនុកបម្រុងលើក
សរសើរករិយារបស់ខ្លួនចំពោះមិត្រកក្តិ ដោយការសង្ត្រោះករិយាឲ្យមាន
មុខមាត់តាមសមឆ្លូរ ។ សេចក្តីនេះបញ្ជាក់ឲ្យយើញថាស្វាមីមានចិត្តស្មោះ
ត្រង់ចំពោះករិយារបស់ខ្លួន បើកឧកាសឲ្យករិយាមានសិទ្ធិបរិបូណិក្នុង
ក្របខ័ណ្ឌរបស់ឆូស្រករ ដោយការលើកករិយាឲ្យមានកិត្តិយសក្នុងការ

គ្រប់គ្រងបុត្តធីតា និងផ្ទះសម្បែង រួមរស់ជាមួយគ្នាដោយសុខសាន្តតរៀងទៅ ។

២- អវិមានតា មិនមើលងាយ ។

ពាក្យថា ការមិនមើលងាយ បានដល់ការមិនបន្ទាបបន្ថោកភរិយា ដោយពាក្យសំដី ឬដោយការទុកដាក់ភរិយាដូចទាសកម្មករ ។ ភរិយាជាស្ត្រីគូជីវិតរួមរស់ដោយសុខទុក្ខជាមួយគ្នា ដែលមាតាបិតាបានផ្សំផ្គុំឲ្យជាគូស្រករនឹងគ្នាតាមប្រពៃណីនិយមមកហើយ ។ បុរសជាស្វាមីមិនត្រូវអាងអំណាចកម្លាំងកាយ កម្លាំងប្រាជ្ញារបស់ខ្លួនមកសង្កត់សង្កិនញាំញីភរិយានោះឡើយ ព្រោះថាភរិយា កាលបើស្វាមីប្រមាថមើលងាយ នឹងជាហេតុនាំឲ្យភរិយាបែកចិត្តគំនិតក្នុងផ្លូវស្នេហា កាលបើស្នេហារវាងស្វាមីនិងភរិយាប្រែះឆាហើយ សេចក្តីសុខចម្រើនក្នុងគ្រួសារក៏មិនមាន ។ ការមិនមើលងាយភរិយារបស់ខ្លួន ទើបជាហេតុនាំមកនូវមង្គលសួស្តីទាំងគូស្វាមីភរិយា ទាំងបុត្រប្រុសស្រី ទាំងជនជិតខាងក៏តែងសម្តែងសេចក្តីកោតសរសើរពុំខាន ។

៣- អនតិចរិយា មិនប្រព្រឹត្តក្បត់ចិត្ត ។

ពាក្យថា មិនប្រព្រឹត្តក្បត់ចិត្ត បានដល់ការប្រព្រឹត្តមិនរំលងអំពីភរិយារបស់ខ្លួន ដោយការលបលាក់យកស្ត្រីដទៃមកជាគូស្រករដោយសម្ងាត់ ។ បុរសជាស្វាមីត្រូវពិចារណាឲ្យឃើញទោសដ៏ធ្ងន់ក្នុងការសេព-

គប់ត្រូវនៅតែថា កាលបើអ្នកអាចប្រព្រឹត្តកន្ទួងចិត្តកូនស្រី នៅការប្រព្រឹត្ត
កន្ទួងនោះ ចាត់ថាជាអំពើទុស ។ កាលបើកូនស្រីប្រព្រឹត្តក្បត់ចិត្តរបស់អ្នក
ជាស្វាមីដូច្នោះដែរ តើខ្លួនអ្នកគួរនៅតែប្រកាន់កូនស្រីបានដែរឬ? បុរសជា
ស្វាមី កាលបើមានកាមារាគ្រប់សង្ខ័ត ចិត្តនាំឲ្យចិត្តមានប្រតិពន្ធ ចំពោះស្ត្រី
ដទៃ ត្រូវតែចារណាក្នុងមាត តាមដំណើរដូចពោលហើយប៉ុណ្ណោះជាដើម ។
ការប្រព្រឹត្តក្បត់ចិត្តកូនស្រី នៃធនាមកនូវនូវសេចក្តីវិនាសច្រើនប្រការ មាន
វិនាសទ្រព្យសម្បត្តិ និងសាមគ្គីធម៌របស់គ្រួសារជាដើម ចំណែកឯការ
មិនប្រព្រឹត្តក្បត់ចិត្តកូនស្រីវិញ ក៏រមែងនាំមកនូវនូវសេចក្តីសុខ សាមគ្គី ចម្រុង
ចម្រើនរបស់គ្រួសារជាច្រើនក្នុងបច្ចុប្បន្ននេះ ។

៤- ឥស្សរិយភោសម្ភគ្គ ប្រគល់ភាពជាធំក្នុងផ្ទះ ។

ពាក្យថា ភាពជាធំ បានដល់ការត្រួតត្រាទុកដាក់ទ្រព្យសម្បត្តិ
ចង្ហាប់ចញ្ចាស់លើកូនប្រុសស្រីនឹងកម្មករក្នុងផ្ទះរបស់ខ្លួន ។ ការទទួលទ្រព្យ
សម្បត្តិទុកដាក់ការពារ និង ការគ្រប់គ្រងមនុស្សដែលនៅជាមួយ គួរ
ស្វាមីដូកដាក់ឲ្យភរិយាមានសិទ្ធិស្មើគ្នានឹងស្វាមី ។ ពិតណាស់ គ្រួសារ
ន៏មួយ ។ ទុកដូចជារដ្ឋតូចមួយដែរ ។ រដ្ឋតូចមានក្រសួងគ្រប់
ការជាច្រើន យ៉ាងណាមិញ គ្រួសារ ន៏មួយ ។ ក៏មានមុខការប្រហែល
ក្រសួងរបស់ពួកការយ៉ាងនោះដែរ ។

៥- អលង្ការ ភណ្ឌ ទាន: ផ្តល់គ្រឿងអលង្ការ ។

ការផ្តល់គ្រឿងអលង្ការចំពោះភរិយា ១ក៏ជាស្នេហ៍មុខមួយរបស់ស្វាមី ដែលអាចធ្វើភរិយារបស់ខ្លួនឲ្យមានសេចក្តីសប្បាយ ទាំងជាហេតុទាំងភរិយាមានចិត្តស្មោះត្រង់ អាចប្តូរដំណែរមេរ៉ាស់ជាមួយស្វាមី ។ ពាក្យថាគ្រឿងអលង្ការ សំដៅយកប្រដាប់តាក់តែងខ្លួន ដូចយ៉ាងមាសពេជ្រនិងសំពត់អាវដែលមានតម្លៃ ព្រមទាំងទ្រព្យសម្បត្តិណាមួយជាវបស់ប្រសើរខ្ពង់ខ្ពស់ ។ ទ្រព្យសម្បត្តិគ្រប់យ៉ាង ដែលមានចូលមកប្រើនតែដោយសារកម្លាំងប្រាជ្ញាស្មារតីរបស់ស្វាមី ព្រោះថាបុរសមានការៈជាអ្នកស្វែងរកទ្រព្យបានច្រើនជាងស្ត្រី ព្រោះបុគ្គលដែលឡើងហាន:ទៅជាកុដុម្ពីក ឬគហបតី សេដ្ឋី ក៏ដោយ សារកម្លាំងប្រាជ្ញាស្មារតីរបស់បុរស ។ ជនជាបុរសកាលបើបានធនធានច្រើនហើយ ចាយវាយ ទិញគ្រឿងអលង្ការចំពោះតែខ្លួនឯងមិនតិតជល់ភរិយារបស់ខ្លួនផង មិនឈ្មោះថាមានតុល្យភាពចំពោះភរិយារបស់ខ្លួនទេ ។ បុរសជាស្វាមីដែលមានការៈជាអ្នកស្វែងរកទ្រព្យសម្បត្តិច្រើនជាងភរិយាតិតមែន ប៉ុន្តែបើជាបុរសមានចិត្តលាក់ពំនួចលួចតំនិតអំពីភរិយា ចេះតែលបយកទ្រព្យសម្បត្តិដែលខ្លួនបានទោ: ទៅ១ក៏ជាក់លាក់ក្សាដោយឡែក បុរសជាស្វាមីបែបនេ: ឈ្មោះថាមានចិត្តមិនត្រង់ទឹងភរិយារបស់ខ្លួនឡើយ កាលបើដូច្នេ:សេចក្តីសុខចម្រើនរបស់ត្រួសារមិនអាចកើតមានបានទេ ។ ការផ្តល់គ្រឿងអលង្ការឲ្យភរិយារបស់ខ្លួននេ: ១ក៏ជាកិច្ចវិភ្ជមួយដ៏ប្រសើររបស់ត្រួសារ ដើម្បីជាទីបាយភ្ជាប់

ចិត្តកិយាបស់ខ្លួន ឲ្យជាប់មាំមួនឡើង ព្រោះថាធម្មតាជាតិជាស្ត្រី មានចិត្តប្រាថ្នាស្រឡាញ់ត្រឿងអលង្ការជាទីបំផុត កាលបើបុរសជាស្វាមីបានផ្តល់ត្រឿងរលង្ការឲ្យកិយា ឈ្មោះថាជាអ្នកបានបំពេញសេចក្តីប្រាថ្នាបស់កិយាឲ្យបានសម្រេចដោយពិត ។

កិយាអនុគ្រោះស្វាមីដោយហេតុ ៥ យ៉ាង

១ - សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយល្អ

២ - សុសង្គហិតបរិជនា សង្គ្រោះជនជាញាតិពំងពីរខាងដោយល្អ

៣ - អនតិចារិនី មិនប្រព្រឹត្តក្បត់ចិត្តស្វាមី

៤ - សម្ភតានុរក្ខនា ថែទាំទ្រព្យដែលស្វាមីរកបានមក

៥ - ឧក្ខាអនលសា ជាអ្នកឈ្វាសវៃមិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ។

អធិប្បាយពង្រីកសេចក្តី

១ - សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយល្អ ។

ការចាត់ចែងការងារមាន ៦ យ៉ាងគឺ ការងារក្នុងផ្ទះ ១ ការងារក្រៅផ្ទះ ១ ។ ការងារទាំងពីរយ៉ាងនេះ ត្រូវកិយាចាត់ចែងលែលកដោយល្អ រឿងរាល់ថ្ងៃ ដើម្បីជាជំនួយកម្ចាំងរបស់ស្វាមី មិនត្រូវមើលបំណាំស្វាមីរបស់ខ្លួនឡើយ ។ កិយាតាមបាលីហៅថា គេហស្សាមិនី ដែលប្រែថា

ស្ត្រីម្ចាស់នៃផ្ទះ ឬថាជាមេផ្ទះ ។ ពាក្យថា ការងារក្នុងផ្ទះ ចូលដល់ការណ៍យកចិត្តដែលត្រូវធ្វើដូចយ៉ាងការត្បាញវ៉ែនចាក់ជាដើម ; ការរៀបចំទុកដាក់ឲ្យមានរបៀបក្នុងផ្ទះ ; ការបោសប្រាសខាងក្នុងផ្ទះ ខាងខាងក្រៅផ្ទះ ការបោកគក់សំពត់ អាវនឹងការដាំដំណាំ ; ដើលដំណាំក្នុងភូមិមានការប្រុយដ ; ស្រោចទឹកជាដើម ។ ការខាងក្រៅផ្ទះ ចូលដល់កិច្ចការដែលត្រូវខាត់-ខងទៅឆ្ងាយអំពីផ្ទះ ; ដូចការគ្រួរកាស់ព្រោះស្រូវជាដើម ; កិច្ចការទាំងនេះ គួរតែយកជួយចាត់ចែងស្វាមីកូនប្រុសស្រី ; ឬកម្មករបស់ខ្លួន ។ ការទទួលបដិសណ្ឋារៈ ; ចំពោះភ្ញៀងគ្រប់ជាន់ថ្នាក់ ; ទោះបីភ្ញៀងជាញាតិសន្ធានរបស់ខ្លួនក្តី ; ជាញាតិសន្ធានខាងស្វាមីក្តី ; ឬភ្ញៀវខាងក្រៅពីនេះក្តី ; ក៏គួរស្ត្រីជាតែយ៉ាងត្រូវប្រាស្រ័យទាក់ទងបាន ។

ការងារក្នុងផ្ទះ ឬក្រៅផ្ទះ ; ត្រូវតែយកចាត់ចែងឲ្យបានសម្រេចដោយល្អ ; មិនត្រូវជាអ្នកខ្ជីខ្ជាចំពោះការងាររបស់ខ្លួនទេ ; ព្រោះស្ត្រីដែលមានស្វាមីលោកចាត់ថាជាស្ត្រីមេផ្ទះដោយហេតុថា ; ជាអ្នកត្រូវមើលការខុសត្រូវក្នុងផ្ទះរៀងរាល់ថ្ងៃ ; ត្រូវចេះទុកដាក់លាក់ក្បាច់ត្បាច់ស្រាលក្នុងផ្ទះឲ្យដាច់ចាត់តង់ ; តាមភាពនៃខ្លួនជាអ្នកនៅគ្រប់គ្រងផ្ទះជាប់ជាងស្វាមី ។ ការចេះចាត់ចែងការងារដោយល្អនេះ ; ទុកថាជាកិច្ចអនុគ្រោះដល់ស្វាមីរបស់ខ្លួន ។

២- សុសង្គហិតបរិជនា ; សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ។

ពាក្យថា សង្គ្រោះ បានដល់ការជួយទំនុកបម្រុងផ្ទុងផ្ទុងផ្តើម ដោយប្រាក់
កាសទ្រព្យធនក្តី ដោយទុកាយប្រាជ្ញាប្រាប់ប្រយោជន៍ក្នុងផ្លូវអាជីវៈក្តី ។
ញាតិទាំងពីរពួកនោះ គឺញាតិទាងត្រកូលរបស់ខ្លួន និងញាតិទាងត្រកូល
របស់ស្វាមី គួរកត់យកគោះពាក់ព័ន្ធញាតិទាំងពីរពួកនេះឲ្យស្មើ ។ ត្រូវ
មិនត្រូវទុកចិត្តស្គាល់ចំពោះតែញាតិរបស់ខ្លួនម្យ៉ាងឡើយ ត្រូវជាអ្នកចេះទុក
ដាក់ខ្លួនឲ្យស្មោះស្ម័គ្រឲ្យជាទីស្រឡាញ់ពេញចិត្តនៃញាតិទាំងពីរចំណែក។

៣- អនតិចារិធី មិនប្រព្រឹត្តក្បត់ចិត្តស្វាមី ។

ពាក្យថា មិនប្រព្រឹត្តក្បត់ចិត្ត បានដល់ការមិនប្រព្រឹត្តរៀចវៃ មិន
ប្រព្រឹត្តកន្ទ្ធិចិត្តរបស់ស្វាមីដោយការសេពគប់ទឹងបុរសដទៃ ក្នុងផ្លូវមេ-
ជុនធម្ម ។ ស្ត្រីដែលមានស្វាមី កាលបើត្រូវកាមពាគ្រលួសក្ត្ត់ចិត្តត្រូវគិត
ឲ្យយើញវ៉ែងធ្ងាយក្នុងពេលនោះភ្លាម ។ ថា បើអាត្មាអញប្រព្រឹត្តកន្ទ្ធិចិត្ត
ស្វាមីខុសប្រពៃណីដូច្នេះ តើការប្រព្រឹត្តកន្ទ្ធិនោះ នាំមកនូវសេចក្តីសុ ។
ឬនាំមកនូវសេចក្តីទុក្ខ? កាលបើស្វាមីប្រព្រឹត្តក្បត់ចិត្តរបស់អញដូច្នេះដែរ
តើខ្លួនអញគួរចោទប្រកាន់ស្វាមីបានដែរឬ ? ស្ត្រីជាកត់យ៉ាងរបស់បុរស
តាមផ្លូវការហើយ កាលបើហ៊ានប្រព្រឹត្តក្បត់ចិត្តស្វាមី ប្រាកដជាបានទូ
សេចក្តីនាស់ខ្លួនឯង ព្រមទាំងទ្រព្យសម្ត្ត្ត្ត្ត្ត្ត្ត
ទៅជាស្ត្រីទ្ចប់ឈ្មោះអស់មួយជាតិ ។

៤- សម្ភតានុរក្ខ្ធ ថែទាំទ្រព្យដែលស្វាមីកេចានមក ។

ទ្រព្យសម្បត្តិតិចឬច្រើនដែលស្វាមីរកបាន ឬខ្ជួនជាកន្សោកបានត្រូវ
ចេះទុកដាក់ឲ្យគង់ មិនត្រូវធ្វេសប្រហែសមិនត្រូវខ្ជះខ្ជាយមិនត្រូវធ្វើខ្ជួនឲ្យ
ជាស្រីកញ្ជើធ្ងុ ។ កញ្ជើឬកូមធ្នាំ ១ កាលបើធ្ងុះធ្ងាយហើយ គោះប៉ាតដាក់
ទីកន្លែងក៏ទីកន្លោះគង់នៅមិនបានយូរទេ ។ តែងហូរស្រក់ចេញអស់ទៅ
ភ្លាម ។ សេចក្តីនេះ យ៉ាងណាមិញ ទ្រព្យសម្បត្តិដែលនៅក្នុងដៃរបស់មនុស្ស
កញ្ជើធ្ងុ ក្អមធ្នាំងធ្ងុ ក៏រមែងធាប់អស់ទៅយ៉ាងនោះដែរ ។ ស្ត្រីជាកន្សោ
ដែលបានតាមថា ជាមេផ្ទះត្រូវជាអ្នកចេះថែទាំទុកដាក់ការពារទ្រព្យសម្បត្តិមិន
ឲ្យវិនាស ។ កន្សោច្រើនតែនៅជាប់ក្នុងផ្ទះ មិនសូវដើរចេញទៅណាយូ
ពេកលក្ខណៈទេ ត្រូវជាអ្នកនៅចាំផ្ទះ ។ ក្រៅពីនេះ ជាងស្វាមីព្រោះហេតុនោះ
ការហោ ត្រូវមានស្មារតី ក្នុងការគ្រប់គ្រងផ្ទះសម្បែងដោយហ្មត់ចត់ មិនត្រូ
ធ្វេសប្រហែសឲ្យសោះ ត្រូវប្រយ័ត្នចំពោះអនុក្ខយគ្រប់យ៉ាង ។ មានអនុក្ខយ
អំពីភ្លើងជាដើម ។

៥- ទ្ធ អ្ន លសា ជាអ្នកឈ្លាសវៃមិនខ្ជិលច្រអូសក្នុងកិច្ច
ការ ។

ស្ត្រីដែលមានស្វាមី ឬបុរសដែលមានកន្សោ ក្នុងលោកនេះ ឈ្មោះថាជា
អ្នកចាប់ផ្តើមកសាងដីវិតថ្មី ។ ខុសប្លែកអំពីកាលដែលខ្ជួនមិនទាន់មានស្វាមី
ការ ។ ព្រោះហេតុនោះ ស្ត្រីជាកន្សោ ត្រូវបណ្តុះគំនិតថ្មីដោយការភ្ញាក់រលឹ
ក ។ ១ ជាអ្នកជាងវៃ ប៉ុនប្រសប់ក្នុងផ្ទះ ។ ២ ជាអ្នកមានវិនិត្រប់យ៉ាងគឺ ១ ជាងបានកសិកម្ម

ខាងពាណិជ្ជកម្មក្តី ត្រូវជាអ្នកមានព្យាយាមខ្មីឃ្មាតចំពោះកិច្ចការទាំងពួង រៀងរាល់ថ្ងៃ មិនត្រូវបណ្តោយខ្លួនឲ្យទៅជាមនុស្សខ្ជិលច្រអូសត្រូវលៃលក ត្រិះរិះគិតគូរកម្មករទម្រមទំពោះកិច្ចការនោះឡើយ ។ កិច្ចការទាំងអស់ គេត្រូវធ្វើដោយកម្លាំងប្រាជ្ញានិងកម្លាំងព្យាយាម ទើបការនោះសម្រេចផលដោយល្អទៅបាន ។ គូស្វាមីភរិយា កាលបើមានឧបាយប្រាជ្ញាឈ្លាសវៃ មានសេចក្តីព្យាយាមប្រឹងប្រែងមានមារយាទល្អប្រាសចាកផ្លូវអបាយមុខ ទើបគ្រប់គ្រងគ្រួសាររបស់ខ្លួនបានសេចក្តីសុខចម្រើនឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ននេះពុំខាន ។ សមដូចពុទ្ធភាសិតដែលមានមកក្នុងគម្ពីរអង្គុត្តរនិកាយថា បុគ្គលដែលបានទទួលឋានៈជាអ្នកមានទ្រព្យ មានយសបរិវារ ព្រោះប្រកបដោយទិដ្ឋធម្មិកត្ថៈ គឺប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាងគឺ ៖-

១) ឧដ្ឋានសម្បទា ការបរិបូណ៌ដោយសេចក្តីប្រឹងប្រែងប្រាសចាកសេចក្តីខ្ជិលច្រអូស

២) អារក្ខសម្បទា បរិបូណ៌ដោយការរក្សា

៣) កល្យាណមិត្តតា ការសេពគប់មិត្រល្អ

៤) សមជីវិតា រស់នៅស្មើល្អ គឺភាពជាអ្នកចេះលៃលកសំចៃចាយវាយល្មមល្អ ក្នុងការចិញ្ចឹមជីវិត ដោយស្គាល់ប្រមាណគ្រប់យ៉ាង ។

បុរសស្ត្រីជាគូស្រករនឹងគ្នា នឹងត្រូវមានបុត្តធីតាដែលកើតអំពីខ្លួន ព្រោះហេតុនោះការចិញ្ចឹមជីវិត ពុំមែននៅត្រឹមតែពីរនាក់ស្វាមីភរិយាប៉ុណ្ណោះ

ឡើយ គឺត្រូវមានការចិញ្ចឹមជីវិតកូនប្រុសស្រីដែលចេះវតវីកតទៅទៀត ។

តូស្វាមីភរិយាជាបុគ្គលមានការៈដ៏ធ្ងន់ក្នុងការចិញ្ចឹមជីវិត ដោយហេតុមានការចាយវាយក្នុងការចំនុកបម្រុងកូនស្រីនិងមាតាបិតារបស់ខ្លួន មួយទៀត យកវាសធមិ គឺការនៅត្រប់ត្រងផ្ទះសំដៅយកភាពនៃជនត្រហស្ថនេះ ជាការតឹងចង្អៀតណាស់ពុំមែនធូរស្រាលទេ ។ អាស្រយ័ហេតុដូចរៀបរាប់មកនេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់សំដែងតិហិវត្ត គឺជាកិច្ចវត្តសម្រាប់ត្រហស្ថដែលមានត្រូសារ ដើម្បីឲ្យត្រហស្ថជាអ្នកចាក់ចងនឹងគ្នាជាគូ ៗ នឹងគ្នា ប្រតិបត្តិឲ្យបានសេចក្តីសុខចម្រើនក្នុងផ្នកត្រហស្ថ ដូចសេចក្តីវែកញ្ចកអធិប្បាយមកនេះឯង ។

កិច្ចវត្តនៃស្វាមីភរិយា ចប់តែប៉ុណ្ណេះ ។

ប្រស្នាព្រះបាទបាយាសិរាជញ:

លោក ប ប ធៀបរ៉ៀង

ព្រះបាទបាយាសិខ្ញុសសួរព្រះកុមារកស្សបត្ថេរថា[១] បពិត្រព្រះកស្សប ដ៏ចំរើន ខ្ញុំតែងនិយាយតាមយោបល់យល់ឃើញថា លោកដទៃឬលោកខាងមុខគ្មានទេ ពួកសត្វកើតឯងដ៏គ្មានទេ ផលរបស់កម្មល្អឬអាក្រក់គ្មានទេ ។

ព្រះកុមារកស្សបត្ថេរហ៊ាយព្រះភាវថា បពិត្រកសាជញ: អាត្មាភាពបានឮសំដីគេជ្រាប់និយាយយ៉ាងនេះដែរ ប៉ុន្តែមិនសមបើគេនិយាយដូច្នេះសោះ ក្នុងរឿងនោះ អាត្មាភាពសូមខ្ញុសសួរមហាបពិត្រវិញ តើព្រះអង្គទ្រង់សំគាល់ថា ព្រះចន្ទនិងព្រះអាទិត្យនៅក្នុងលោកនេះ ឬក៏នៅក្នុងលោកដទៃ ជាទេវតាឬជាមនុស្ស ?

ចា[២] ព្រះចន្ទនិងព្រះអាទិត្យនេះនៅក្នុងលោកដទៃ មិនមែននៅក្នុងលោកនេះទេ ជាទេវតា មិនមែនជាមនុស្សទេ ។

ក - [៣] បើតាមព្រះបន្ទូលនេះ សូមមហាបពិត្រមានយោបល់យល់ឃើញថា លោកដទៃមាន ពួកសត្វកើតឯងមាន[៤] ផលរបស់កម្មល្អឬអាក្រក់មាន យ៉ាងនេះវិញ ?

ចា - ព្រះកស្សបដ៏ចំរើនគោលយ៉ាងនេះ ក៏ត្រូវម្ល៉ាងដែរហ៊ាយ ប៉ុន្តែ ខ្ញុំនៅតែយល់ឃើញដូចមុនដដែល ។

---

១) ស្រង់ពីគម្ពីរសេចក្ដីទី ២ អំពីសុត្តន្តបិដក ទីឃនិកាយ ចតុត្ថភាគ មហាវគ្គ បាយាសិរាជញ្ញសូត្រ (សៀវភៅព្រះត្រៃបិដកជាភាសាខ្មែរ លេខទី ១៣) ។ ២) ព្រះបាទបាយាសិរាជញ: សួរ ។ ៣) ព្រះកុមារកស្សបត្ថេរឆ្លើយ ។ ៤ ១ឧបបាតិកសត្ត ។

ក្ - ចុះមានរឿងកំណត់ដូចម្តេច ដែលជាហេតុនាំឲ្យមហាបពិត្រយល់ឃើញដូច្នោះ ?

ចា - ពួកមិត្ត អមាត្យនិងញាតិសាសន៍លោកហ៊ីតរបស់ទ្រង់ក្នុងលោកនេះជាអ្នកសម្ងាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសកន្លងកាម និយាយកុហកនិយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់ចាន ទ្រព្យគេ មានចិត្តគំនុំគេ មានសេចក្តីយល់ឃើញខុស ពួកមិត្រអមាត្យជាដើមនោះ លុះសម័យវាងរាត្រីមក មានជម្ងឺឈឺធ្ងន់ត្រូតខ្យល់ មិនដាច់ មុខជាស្លាប់មិនខាន ទ្រឹកចាន់ចូលទៅកពួកមិត្រអមាត្យទាំងនោះ ហើយនិយាយថា នែអ្នកដ៏ចំរើន មានសមណព្រាហ្មណ៍ពួកមួយនិយាយថា ពួកជនណាសម្ងាប់សត្វ លួចទ្រព្យគេ ។ល។ មានសេចក្តីយល់ឃើញខុស ពួកជននោះ លុះស្លាប់ហើយកែងទៅកើតក្នុងកំណើតតិរច្ឆានប្រភេទវិស័យអសុរកាយនរកដូច្នេះ ឯអ្នកដ៏ចំរើនទាំងឡាយសុទ្ធតែជាអ្នកសម្ងាប់សត្វ លួចទ្រព្យគេ ។ល។ មានសេចក្តីយល់ឃើញខុសហើយ ម្យ៉ាងពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះពិតមែន អ្នកដ៏ចំរើនទាំងឡាយ លុះស្លាប់ហើយ មុខជាកើតក្នុងកំណើតតិរច្ឆាន ប្រភេទវិស័យ អសុរកាយ នរកពុំខាន ម្យ៉ាងទៀត ប្រសិនបើអ្នកទាំងឡាយស្លាប់ហើយទៅកើតក្នុងកំណើតតិរច្ឆានប្រភេទវិស័យ អសុរកាយ នរកមែន អ្នកទាំងឡាយត្រូវមកប្រាប់យើងវិញว่า លោកដ៏វិសេសៗ ពួកសត្វកើតឯងដ៏មាន ដ្ឋានៈ ដ្ឋានៈ ... ...

ដោយហេតុនេះ ព្រោះថាអ្នកទាំងឡាយជាបុគ្គលដែលខ្ញុំគួរជឿ គួរទទួលស្តាប់ពាក្យបាន ហេតុឯណាដែលអ្នកទាំងឡាយបានឃើញហើយ ហេតុនុ៎ះទីងទុកដូចជាខ្ញុំបានឃើញ បំពោះខ្លួនឯងដែរ ពួកមិត្រអមាត្យទាំងនោះទទួលពាក្យរបស់ខ្ញុំថា ព្រះករុណាវិសេស ដូច្នេះហើយស្តាប់ទៅតែមិនឃើញមកប្រាប់ខ្ញុំវិញ ទាំងមិនប្រើបម្រើមកប្រាប់ខ្ញុំសោះឡើយ បាត់ស្ងាត់ឈឹងស្ងៀមទៅ រឿងនេះឯងដែលជាហេតុនាំឲ្យខ្ញុំមានគំនិតយល់ឃើញថា លោកដទៃគ្មានទេ ពួកសត្វកើតឯងគ្មានទេ ផលរបស់កម្មល្អឬអាក្រក់គ្មានទេ ។

ក - ថ្វាយព្រះពររាជញ្ញៈ បើដូច្នោះ អាត្មាភាពសូមទូលសួរមហាបពិត្រក្នុងរឿងនុ៎ះវិញថា ពួករាជបុរសរបស់មហាបពិត្រក្នុងដែននេះចាប់បានចោរដែលប្រព្រឹត្តអាក្រក់មកថ្វាយមហាបពិត្ររួចក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ទ្រង់សព្វព្រះហឫទ័យនឹងដាក់អាជ្ញាណាដល់ចោរនេះ សូមដាក់អាជ្ញានោះមក ទើបមហាបពិត្រមានព្រះបន្ទូលនឹងរាជបុរសទាំងនោះថា បើដូច្នោះ អ្នកទាំងឡាយចូរនាំគ្នាចងស្លាបសេកបុរសនេះ ឲ្យខ្ជាប់ដោយខ្សែដ៏មាំហើយកោរក្បាលឲ្យរលីងចេញ រួចត្រូវខ្ទូងស្គរជ័យឲ្យឮយ៉ាងខ្លាំងនាំបណ្តើរជុំវិញសព្វច្រកល្ហក សព្វផ្លូវបំបែក រួចនាំចេញទៅតាមទ្វារខាងត្បូង កាត់ក្បាលត្រង់កន្លែងសម្រាប់ពិឃាដ ឯខាងត្បូងនគរចុះ រាជបុរសទាំងនោះ

ក៏ខ្ជួលធ្វើតាមព្រះពាដនុង្ហារគ្រប់ប្រការ ។ កាលពួកពាដបុរសឲ្យចោរនោះ
អង្គុយត្រង់ឥន្ទ្រីតសម្រាប់សម្ងាប់ហើយ ចុះចោរនោះនឹងអង្វរពួកពេជ្ជ-
ឃាតថា សូមពួកពេជ្ជឃាតបង្ហូរឈាមសិន ព្រោះពួកមិត្រអមាត្យទាំងញាតិ
សាសោហិតរបស់ខ្ញុំមាននៅក្នុងស្រុកឋានគមងណោះ ចាំខ្ញុំផ្តាំដល់ពួក
មិត្រអមាត្យទាំងនោះសិន ហើយសឹមមកវិញ ដូច្នេះតើបានដែរឬទេ ឬក៏
ពួកនាយពេជ្ជឃាតទាំងនោះ ទាំងចេះតែកាត់ក្បាលចោរដែលកំពុងខ្ជួញយ
ដោយឥតយោគយល់សោះនោះទៅវិញ ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន ចោរនោះនឹងអង្វរពួកពេជ្ជឃាត
ដូច្នោះមិនបានឡើយ តាមពិតពួកពេជ្ជឃាតនឹងចេះតែកាត់ក្បាលចោរ
ដែលកំពុងខ្ជួញនោះឲ្យភ្លាមតែបាន ។

ក - ម្ចាយព្រះពរពាដញ: អម្បាលយ៉ាងចោរនោះជាមនុស្សជាតិដូច
គ្នាត្រឡប់ង ម្តេចតង់អង្វរពួកពេជ្ជឃាតជាមនុស្សជាតិដូចគ្នាមិនបានទៅ
ហើយ ចំណង់បើពួកមិត្រអមាត្យញាតិសាសោហិតរបស់មហាបពិត្រ សុទ្ធ
តែជាអ្នកសម្ងាប់សត្វ ស្ងួចត្រាត្យតេ ។បេ។ មានសេចក្តីយល់ឃើញខុស
ស្ងុះស្ងាប់ហើយទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយនរក
ហើយ ធ្វើម្តេចឡើយនឹងអង្វរពួកនាយនិរយបាលថា សូមពួកនាយនិរយ-
បាលដ៏ចំរើនបង្ហូរឈាមសិន ចាំយើងតាំងឆ្ងាយទៅគ្រាបទូលដល់ព្រះបាទ
ចាយាសិកដញ:ថា លោកដ៏ចំរើន ពួកសត្វកើតឯងមាន ផលរបស់កម្ម

ស្ត្រីអាក្រក់មាន ដោយហេតុនេះដូច្នេះបាន ឆ្ពោះជ្ញ: បើតាមរឿងវ៉ានេះ ឯង សូមមហាបពិត្រមែរព្រះយោបល់យើញថា លោកដ៏ទៃមាន ពួកសត្ត កើតឯងមាន ផលរបស់កម្មស្ត្រីអាក្រក់មានយ៉ាងនេះវិញ ។

ចា - ព្រះកស្សបដ៏ចំរើនពោលយ៉ាងនេះ ក៏ត្រូវម្យ៉ាងដែរហើយ ប៉ុន្តែ ខ្ញុំនៅតែយល់យើញក្នុងហេតុនុ៎ះដូចដើមដដែល ។

ក - ថ្វាយព្រះពរកជ្ញ ចុះនៅមានរឿងម្យ៉ាងទៀតដែរឬ ដែលជា ហេតុនាំឲ្យព្រះអង្គយល់យើញថា លោកដ៏ទៃគ្មាន ពួកសត្ត្វកើតឯងគ្មាន ផលរបស់កម្មស្ត្រីអាក្រក់គ្មានដូច្នេះ សូមមហាបពិត្រមានព្រះបន្ទូលទៅ មើល ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន ពួកមិត្រអមាត្យនិងញាតិសាលោហិត របស់ខ្ញុំក្នុងលោកនេះ ជាអ្នកវៀរចាកចាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀ-រចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ គ្មានអភិជ្ឌា គ្មានចិត្តព្យាបាទ ជា សម្មាទិដ្ថិ លុះសម័យបន្ទាប់ក្រោយមក ពួកមិត្រអមាត្យទាំងនោះមានជម្ងឺឈឺ ធ្ងន់ជិតស្លាប់ ខ្ញុំដឹងហើយក៏ចូលទៅនិយាយផ្តែផ្តាំពួកមិត្រអមាត្យទាំងនោះ ថា នែអ្នកដ៏ចំរើនមានសមណព្រាហ្មណ៍ពួកមួយនិយាយថា ពួកជនណា វៀរចាកចាណាតិបាត ។បេ។ ជាសម្មាទិដ្ថិ ពួកជននោះ លុះស្លាប់ហើយ តែងទៅកើតនៅស្ថានសួគ៌ដូច្នេះ ឥឡូវនេះអ្នកដ៏ចំរើនទាំងឡាយសុទ្ធតែជា

អ្នកវៀរចាកចាណាតិចាត ។បេ។ ជាសម្ចាទិដ្ឋិហើយ បើជាពាក្យសមណ ព្រាហ្មណ៍ទាំងអស់នោះពិតមែន អ្នកដ៏ចំរើនទាំងឡាយ លុះស្លាប់ហើយ មុខជាទៅកើតនៅស្ថានសួគ៌ពុំខាន បើអ្នកទាំងឡាយចានៈទៅកើតឯស្ថានសួគ៌មែន អ្នកពាល់ត្នាចូរមកប្រាប់យើងវិញថា លោកដ៏ខៃមាន ពួកសត្វកើតឯងមាន ផ្លែរបស់កម្មល្អប្អូអាក្រក់មាន ដោយហេតុនេះផ្ទ ឯអ្នកទាំងឡាយជាបុគ្គលដែលយើងគួរជឿ គួរទទួលស្តាប់ពាក្យចាន ហេតុណាដែលអ្នកទាំងឡាយចានយើញហើយ ហេតុនុ៎ះនឹងទុកដូចជាយើងក្ជួនយើញដោយខ្លួនឯងដែរ ពួកមិត្ត្រអមាត្យទាំងនោះទទួលពាក្យខ្ញុំ ថា ការណាវិសេស លុះស្លាប់ហើយមិនយើញត្រឡប់មកប្រាប់ខ្ញុំវិញ ទាំងមិនប្រើប់ារើមកប្រាប់ខ្ញុំផង ព្រោះរឿងកាវនេះឯង ចានជាខ្ញុំយល់យើញ ថា លោកដ៏ខៃគ្មាន ។បេ។

ក - ថ្វាយព្រះពរកជញ្ជៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្ដីឧបមា ថ្វាយមហាបពិត្រ ដ្ឋិតពួកបុរសខ្លះជាអ្នកចេះដឹងក្នុងលោកនេះគង់យល់សេចក្ដីនៃកាសិតដោយពាក្យឧបមាចាន បពិត្រកជញ្ជៈ ប្រៀបដូចជាបុរសលិចចុះត្រមាទាំងក្ជាលទៅក្នុងរណ្ដាលមក ត្រានោះ មហាបពិត្រចានត្រាស់បង្ហាប់ពជបុរសទាំងឡាយថា ចូរអ្នកទាំងឡាយស្រង់បុរសនោះអំពីរណ្ដាលមកឡើង យកចម្រៀកបូស្ស្ម៉ែមកកោសកៀរលាមក អំពីខ្លួនបុរសនោះឲ្យស្អាតចាកចេញ ចូរយកដ៏ស្ងួតពណ៌ស្ងៀងមកដុសលាងខ្លួន បុរស

នោះឲ្យបានប៉ាន់ ចូរយកប្រេងលាបបុរសនោះ ហើយយកគ្រឿងលំអិត ដ៏ម៉ដ្ឋនៅទាត់ឲ្យស្អាតបាតបានប៉ាន់ ចូរកាត់សក់ទាំងពុកមាត់របស់បុរសនោះចេញយកផ្ការកម្រងមានថ្លៃច្រើន យកគ្រឿងលាបមានថ្លៃច្រើន ទាំងសំពត់ចាំងភ្លាយទៅប្រគល់ឲ្យបុរសនោះចុះ ចូរឲ្យបុរសនោះឡើងទៅលើប្រាសាទ ហើយចាត់ចែងនូវតាមគុណទាំង ៥ ឲ្យពួកពាជបុរសកំពុងធ្វើតាមព្រះពាជបញ្ជាគ្រប់ប្រការ តើមហាបពិត្រសំគាល់ហេតុនោះយ៉ាងដូចម្តេច ? កាលបើបុរសនោះបានងូតទឹកស្អាតបាត ហើយលាបខ្លួនស្រួលបួល កាត់សក់ការពុកមាត់ស្រេចហើយ ពាក់គ្រឿងប្រដាប់តែមណី ស្លៀកសំពត់សរួចហើយឡើងទៅលើប្រាសាទដ៏ប្រសើរ ឲ្យគេបំរើផ្ចង់ផ្ចង់ដោយតាមគុណទាំង ៥ ដូច្នេះតើបុរសនោះ នៅតែចង់ចុះទៅកន្លែងណ្ណាលាមកនោះវិញទៀតដែរឬទេ ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន បុរសនោះមិនត្រូវការចុះទៅកន្លែងណ្ណាលាមកនោះវិញទៀតទេ ។

ក - ចុះដំណើរនោះ តើព្រោះហេតុដូចម្តេច ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន ព្រោះណ្ណាលាមកមិនជាទីពេញចិត្ត ជារបស់មិនស្អាតផង ជាចំណែកនៃរបស់មិនស្អាតផង មានក្លិនស្អុយផង ជាចំណែកនៃរបស់មានក្លិនស្អុយផង ជារបស់គួរធុញទ្រាន់ផង ជាចំណែកនៃរបស់គួរធុញទ្រាន់ផង ជារបស់គួរខ្ពើមរអើមផង ជាចំណែកនៃរបស់គួរខ្ពើមរអើមផង ។

ក - ថ្វាយព្រះពរភន្តៈ យ៉ាងហ្នឹងមែនហើយ ដូចគ្នានឹងមនុស្សពាំងឡាយជារបស់មិនស្អាតផង មានកូនស្អុយផង គួរធុញទ្រាន់ផង គួរខ្ពើមរអើមផង ដល់ទេវតាពាំងឡាយ បពិត្រភន្តៈ កូនមនុស្សធ្ងុំស្អុយហុយផ្សាយទៅដល់ស្ថានទេពតាមួយ ១០០ យោជន៍ ពួកមិត្រអមាត្យនឹងញាតិសាលោហិតរបស់មហាបពិត្រជាអ្នកវៀរចាកចុណ្ណាតិចុតៗ ។បេ។ ជាសម្ចាទិដ្ថ លុះស្លាប់ហើយចូលទៅកើតនៅស្ថានសួគ៌ ទ្រង់មកប្រាប់ព្រះអង្គว่า លោកដ្ឋានមាន ពួកសត្វកើតឯងមាន ផលរបស់កម្មល្អអាក្រក់មាន យ៉ាងនេះដូចម្តេចកើត ឯកជ្ញៈ បើតាមរឿងក៏ដូចនេះ សូមមហាបពិត្រមេត្តាយ៉ាងលល់ឃើញว่า លោកដ្ឋានមាន ។បេ។ ដូច្នេះវិញ ?

ចា - ព្រះកស្សបដ៏ចំរើនពោលយ៉ាងនេះ ក៏គួរម្ល៉ាងដែរហើយ ប៉ុន្តែ ខ្ញុំនៅតែយល់ឃើញដូចដើមដដែល ។

ក - ថ្វាយព្រះពរភន្តៈ ចុះនៅមានរឿងក៏ដូចម្តេច ដែរឬទេ បើមានសូមមហាបពិត្រមានព្រះបន្ទូលទៅមើល ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន នៅមានរឿងក៏ដូចជាว่า ពួកមិត្រអមាត្យនិងញាតិសាលោហិតរបស់ខ្ញុំកន្លងលោកនេះ ជាអ្នកវៀរចាកចុណ្ណាតិចុតៗ ។បេ។ វៀរចាកសុភមេរយមជ្ឈឃ្ងាងដ្ឋាន លុះសម័យខាងក្រោយមក ពួកមិត្រអមាត្យជាដើមនោះ មានជម្ងឺឈឺជាខ្លាំងដាក់ស្លាប់ ខ្ញុំក៏ចូលនិយាយว่า មានសមណៈព្រាហ្មណ៍ពួកមួយនិយាយតាមគំនិតយល់ឃើញ

ថា ពួកជនណាជាអ្នកវៀរចាកបាណាតិបាត ។ល។ វៀរចាកសុរាមេរ័យ ជននោះ លុះស្លាប់ហើយតែងបានទៅកើតឯស្ថានសួគ៌ ឥឡូវនេះ ពួកអ្នកបានវៀរចាកបាណាតិបាត ។ល។ វៀរចាកសុរាមេរ័យ បើពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះពិតមែន អ្នកទាំងឡាយស្លាប់ហើយមុខជាបានទៅកើតនៅស្ថានសួគ៌ជាន់តាវតិង្សពុំខាន បើពួកអ្នកបានទៅកើតនៅស្ថានសួគ៌ស្រេចហើយត្រូវត្រឡប់មក ប្រាប់យើងវិញផងថា លោកដទៃមាន ។ល។ ត្បិតពួកអ្នកជាបុគ្គលដែលយើងគួរជឿ យើងគួរទទួលស្តាប់ពាក្យបាន ហេតុណាដែលអ្នកពល់គ្នាបានឃើញហើយ ហេតុនុ៎ះទុកដូចជាយើងបានឃើញផ្ទាល់ខ្លួនឯងដែរ ពួកមិត្រអមាត្យទាំងនោះបានទទួលពាក្យបណ្តាំខ្ញុំរួចហើយក៏ស្លាប់ទៅ មិនដែលឃើញអ្នកណាម្នាក់មកប្រាប់ខ្ញុំវិញសោះ ទាំងមិនប្រើបំរើមកប្រាប់ខ្ញុំផង រឿងនេះឯងដែលនាំឲ្យខ្ញុំយល់ឃើញថាលោកដទៃគ្មានទេ ។ល។

ក - ថ្វាយព្រះពរកេជ្ញៈ បើដូច្នោះ អាត្មាភាពសូមទូលសួរមហាបពិត្រវិញថា មួយរយឆ្នាំរបស់មនុស្ស ត្រូវជា១យប់១ថ្ងៃរបស់ទេវតាជាន់តាវតិង្ស រាប់រាត្រីនោះបាន៣០រាត្រីត្រូវជា១ខែ រាប់ខែនោះបាន១២ខែត្រូវជា១ឆ្នាំ រាប់ឆ្នាំនោះបានមួយពាន់ឆ្នាំទិព្វជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវតិង្ស ពួកមិត្រអមាត្យនិងញាតិសាលោហិតឯណាជាអ្នកវៀរចាកបាណាតិបាត ។ល។ លុះស្លាប់ហើយបានទៅកើតនៅស្ថានសួគ៌ជាន់

តាវតិង្ស ចុះបើពួកមិត្រអមាត្យទាំងនោះគិតថា ចាំយើងទាំងឡាយឲ្យគេបំរើឲ្យផ្គែតផ្គង់ដោយកាមគុណទាំង៥ជាទិព្យអស់ពីរឬបីថ្ងៃសិន រួចសឹមយើងទៅប្រាប់ព្រះបាទបាយាសិរាជញ្ញៈថា លោកដទៃមាន ។បេ។ ចុះពួកមិត្រអមាត្យទាំងនោះមកទូលមហាបពិត្រទាន់ដែរឬទេ ?

បា- បពិត្រព្រះកស្សបដ៏ចំរើន គេមកប្រាប់ខ្ញុំមិនទាន់ទេ បានជាគេមកប្រាប់មិនទាន់នោះ ព្រោះថាខ្ញុំមុខជានឹងស្លាប់បាត់ទៅមុនគេយូរណាស់ទៅហើយ ចុះអ្នកណាមកប្រាប់ដំណឹងនេះដល់ព្រះកស្សបដ៏ចំរើនថា ពួកទេវតាជាន់តាវតិង្សមាន ឬថាពួកទេវតាជាន់តាវតិង្សមានអាយុវែងយ៉ាងនេះ យើងមិនទាន់ជឿព្រះកស្សបថា ពួកទេវតាជាន់តាវតិង្សមាន ឬថាពួកទេវតាជាន់តាវតិង្សមានអាយុវែងយ៉ាងនេះទេ ។

ក- ថ្វាយព្រះពររាជញ្ញៈ ប្រៀបដូចជាបុរសខ្វាក់ពីកំណើត មិនដែលឃើញរូបខ្មៅឬស មិនដែលឃើញរូបដែលមានសម្បុរខៀវលឿងក្រហមហង្សបាទ មិនដែលឃើញរបស់ស្មើនិងមិនស្មើ មិនដែលឃើញរូបផ្កាយទាំងឡាយ មិនដែលឃើញព្រះចន្ទនិងព្រះអាទិត្យទេ មនុស្សខ្វាក់នោះមុខជានឹងនិយាយថា រូបខ្មៅឬសគ្មានទេ បុគ្គលអ្នកឃើញរូបខ្មៅឬសគ្មានទេ រូបខៀវគ្មានទេ ។បេ។ ព្រះចន្ទនិងព្រះអាទិត្យគ្មានទេ បុគ្គលអ្នកឃើញព្រះ-ចន្ទនិងព្រះអាទិត្យគ្មានទេ អញមិនស្គាល់របស់នុ៎ះ អញមិនឃើញរបស់នុ៎ះ

ហេតុដូច្នោះ បស់នោះគ្មានទេ កាលបើអ្នកភ្ជាក់ពីកំណើតនិយាយនោះ ឈ្មោះថា គេនិយាយត្រូវដែរឬទេ ?

ចា - បពិត្រព្រះកស្សបដ៏ចំរើន មិនត្រូវទេ ព្រោះប្រៀបដូចសមានអ្នក យើញប្រៀបដូចសមាន ។ល។ ព្រះចន្ទ្រព្រះអាទិត្យមាន អ្នកយើញព្រះចន្ទ្រ ព្រះអាទិត្យមាន កាលបើបុរសភ្ជាក់ពីកំណើតនិយាយថា អញមិនស្គាល់ បស់ទ្ធ អញមិនយើញ បស់ទ្ធ ព្រោះហេតុនោះ បស់នោះគ្មានទេ ដូច្នេះ ឈ្មោះថា គេនិយាយមិនត្រូវសោះឡើយ ។

ក - ថ្វាយព្រះពរ ភ្ជាញ យ៉ាងហ្នឹងមែនហើយ អគ្គមហាបពិត្រ ទ្ធ ដូច ជាមនុស្សភ្ជាក់ពីកំណើតពិតប្រាកដ ចានជាមហាបពិត្រ ស្ដាប់ថា ចុះមាន អ្នកណាមកប្រាប់ដំណឹងនេះដល់ព្រះកស្សបថា ពួកទេវតាជាន់តាវ តឹង្ស មាន ឬថា ពួកទេវតាជាន់តាវតឹង្ស មានអាយុវែងយ៉ាងនេះ យើងមិនជឿ ពាក្យ បស់ព្រះកស្សបថាដូច្នេះទេ ព្រះអគ្គ សំ គាល់ដោយ ម៉ាសចក្ខុ នេះ យ៉ាង ណា ឯ លោ ក ដ ទៃ ប ុ គ្គ ល ម ិ ន ត ប្ប ី យើ ញ ចា ន យ ៉ា ង នោ ះ ឡ ើ យ ពួ ក ស ម ណ ព្រាហ្មណ៍ណាអាស្រ័យ ស ន ានៈ ពាំ ង ឡ ាយ ដ ី ស្ងាត់ ដែ ល ពាំ ង នៅ ក្ន ុ ង ព្រ ៃ ភ ូ ច ន ិ ង ព្រ ៃ ធ ំ ពួ ក ស ម ណ ព្រ ាហ្ម ណ ៍ ពាំ ង នោ ះ ម ិ ន ប្រ ម ាទ ម ាន ព ្យ ា យ ាម ដ ុ ត ក ំ ដ ៅ ក ិ ល េ ស ម ាន ច ិ ត ្ត ផ ្ត ោ ះ ទ ៅ ក ព្រ ះ ន ិ ញ ្ជ ន ជ ម្រ ុ ះ ទ ូ ទ ៃ ព ្ជ ូ ច ក ្ខ ុ ទ ៅ ក ្ន ុ ង ព្រ ៃ ស្ងាត់ ទ ើ ប យ ើ ញ ល ោ ក ន េ ះ ផ ង ល ោ ក ដ ទ ៃ ផ ង ព ួ ក ស ត ្ត ว ก ើ ត ឯ ង ផ ង ដ ោ យ ច ក ្ខ ុ ដ ូ ច ជ ា ទ ិ ព ្យ ដ ឹ ប ริ ส ุ ท ธ ิ ក ន ្ធ ផ ង ច ក ្ខ ុ ជ ា ប ស ់ ម ន ុ ស ្ស ធ ម ្ម ត ា ឯ ប ុ គ ្គ ล ค ป ្ป ี យ ើ ញ ล ោ ก ด ว ง ย ๊ า ง ห ร ื อ ม ิ ห ร ื อ ม ิ ม ี ม ห า บ ว ก ต ร ส ั ม ค ล ่ า ว ด ้ ว ย

ម៉ាសចក្ខុនេះទេ បើតាមរឿងក៏រនេះ សូមមហាបពិត្រសម្តេចព្រះយោបល់ថា លោកដ្ឋានមាន ។បេ យ៉ាងនេះវិញ ។

ចា - ព្រះកស្សបដ៏ចំរើនពោលយ៉ាងនេះក៏ត្រូវម្យ៉ាងដែរហើយ ប៉ុន្តែខ្ញុំនៅតែយល់ឃើញដូចដើមថា លោកដ្ឋានគ្មានទេ ។បេ។

ក - បពិត្រកញ្ញា: ចុះមានរឿងក៏រអ្វីទៀតដែរឬទេ ដែលជាហេតុនាំឲ្យមហាបពិត្រយល់ឃើញដូច្នោះ សូមមហាបពិត្រមានព្រះបន្ទូលទៅម៉ើល?

ចា - បពិត្រព្រះកស្សបដ៏ចំរើន ក្នុងលោកនេះ ខ្ញុំឃើញពួកសមណព្រាហ្មណ៍មានសីល មានធម៌ល្អ ចង់តែរស់ មិនចង់ស្លាប់សោះ ប្រាថ្នាតែសេចក្តីសុខ ស្អប់ខ្ពើមទុក្ខណាស់ ខ្លួនខ្ញុំត្រិះរិះថា បើពួកសមណព្រាហ្មណ៍ពាំងនេះមានសីល មានធម៌ល្អ ដឹងថាយើងពាំងឡាយ កាលៈបើស្លាប់ពីលោកនេះទៅ មុខជានឹងបានសេចក្តីសុខប្រសើរជាង ឥឡូវនេះពួកសមណព្រាហ្មណ៍ពាំងនេះមានសីល មានធម៌ល្អហើយ គួរតែលេងថ្នាំពិសក្តី យកកាំបិតមកអាកខ្លួនឯងក្តី ចងកសម្លាប់ខ្លួនឯងក្តី លោតចំលាក់ខ្លួនទៅក្នុងជ្រោះក្តី តែពួកសមណព្រាហ្មណ៍ពាំងនេះមានសីល មានធម៌ល្អហើយមិនដឹងថា យើងកាលបើស្លាប់ពីលោកនេះទៅហើយ នឹងបានសេចក្តីសុខប្រសើរជាងដូច្នេះឡើយ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ពាំងនេះមានសីល មានធម៌ល្អហើយ នៅតែចង់រស់ មិនចង់ស្លាប់សោះ ប្រាថ្នាតែសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខណាស់ រឿងនេះ

ឯងដែលនាំឲ្យខ្ញុំចូលចិត្តថា លោកដទៃគ្មានទេ ។ល។

ក - ថ្វាយព្រះរាជញ្ញ: បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្ដីឧបមា ថ្វាយមហាបពិត្រថា កាលពីព្រេងនាយ មានព្រាហ្មណ៍ម្នាក់មានប្រពន្ធពីរ ប្រពន្ធមួយមានកូនប្រុសម្នាក់អាយុ ១០ ឆ្នាំ ឬ ១២ ឆ្នាំ ប្រពន្ធមួយទៀតកំពុងតែមានគភ៌ជិតនឹងសម្រាល ក្នុងពេលនោះព្រាហ្មណ៍ជាស្វាមីធ្វើមរណកាលទៅ មាណពជាកូនបាននិយាយនឹងម្ដាយចុងថា នែអ្នកម្ដាយដ៏ចំរើន របស់ណាគឺទ្រព្យក្ដី ស្រូវក្ដី ប្រាក់ក្ដី មាសក្ដី របស់ទាំងអស់នោះជារបស់ខ្ញុំ ឯអ្នកម្ដាយមិនត្រូវបានចំណែកតិចតួចក្នុងសម្បត្តិនេះទេ សូមអ្នកម្ដាយប្រគល់ទ្រព្យមត៌កជារបស់បិតាឲ្យមកខ្ញុំ ។ នាងព្រាហ្មណីឆ្លើយថា នែកូនចូរចាំបន្តិចសិន ទម្រាំអញសម្រាលកូនរួចសិន បើកូននោះប្រុសនឹងត្រូវបានទ្រព្យបន្តិចបន្តួចដែរ បើកូននោះស្រីនឹងបានធ្វើជាកិរិយារបស់អ្នក ។ មាណពនោះនិយាយសុំសម្បត្តិពីម្ដាយចុងដូចមុនជាគំរប់ពីរដងផង ជាគំរប់បីដងផង ។ លំដាប់នោះឯង នាងព្រាហ្មណីកាន់កាំបិតចូលទៅក្នុងបន្ទប់ហើយវះខ្លួនឯងដោយគិតឃើញថា បើកូនជាប្រុសឬស្រី អញគង់ដឹងច្បាស់បាន នាងព្រាហ្មណីនោះហេតុតែល្ងង់មិនឈ្លាសវៃ ស្វែងរកទ្រព្យមត៌កមិនត្រូវវិធី ក៏ដល់នូវសេចក្ដីវិនាសទាំងខ្លួនឯងផង ទាំងជីវិតផង ទាំងកូនក្នុងគភ៌ផង ទាំងសម្បត្តិផងជាពិតប្រាកដ បពិត្ររាជញ្ញ:(១)ព្រះអង្គជាបុគ្គលល្ងង់មិនឈ្លាសវៃ ស្វែងរកបរលោកខុស

១) ស្ដេចដែលឡើងគ្រងរាជ្យ មិនទាន់ធ្វើរាជាភិសេក ។

ទំនង គង់នឹងដល់នូវសេចក្តីវិនាស ដូចជានាងព្រាហ្មណីដែលល្ងង់មិនឈ្លាសវៃ ស្វែងរកសម្បត្តិខុសទំនង ក៏បែរជាបានដល់នូវសេចក្តីវិនាស ដូច្នោះមិនខាន ៗ បពិត្រភដញ្ញៈ សមណព្រាហ្មណ៍ទាំងឡាយ មានសីល មានធម៌ល្អ មានជីវិតវិសេសជាងពួកជនដទៃ ពួកសមណព្រាហ្មណ៍ មានសីល មានធម៌ល្អស្ថិតនៅអស់កាលយូរអង្វែងដោយប្រការណា ពួកសមណព្រាហ្មណ៍ទាំងនោះរមែងបានបុណ្យច្រើន នឹងប្រតិបត្តិដើម្បីជាប្រ-យោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយដោយប្រការដូច្នោះឯង ៗ ទុកជាញៈ បើតាមរឿងរ៉ាវនេះ សូមមហាបពិត្របែរព្រះយោបល់យល់ថាលោកដទៃមាន ៗ បេ ៗ យ៉ាងនេះវិញ ៗ

បា - ព្រះកស្សបដ៏ចំរើនពោលយ៉ាងនេះក៏គួរស្តាប់ដែរហើយ ប៉ុន្តែខ្ញុំនៅតែយល់ឃើញដូចដើម ៗ

កុ - ចុះមានរឿងរ៉ាវអ្វីទៀត ដែលជាហេតុនាំឲ្យមហាបពិត្រយល់ឃើញដូច្នោះ ?

បា - បពិត្រព្រះកស្សបដ៏ចំរើន មានរឿងរ៉ាវមួយទៀតថា ពួករាជបុរសក្នុងលោកនេះចាប់បានចោរដែលធ្វើអាក្រក់មកបង្ហាញខ្ញុំ ៗ ខ្ញុំក៏បង្គាប់ឲ្យចាប់បុរសនេះទាំងរស់បោះទៅក្នុងខ្ទះហើយគ្របមាត់ខ្ទះ យកស្បែក

ស្រស់ភាសាដាសរួចយកដីស្អិតស៊ីមមកបូកឲ្យក្រាស ហើយលើកដាក់លើដើមក្រានរួចដុតកូន ឯពួកកាដបុរសទាំងនោះក៏ធ្វើតាមបង្គាប់ខ្ញុំគ្រប់ប្រការ ។ កាលដែលយើងដឹងថាបុរសនោះស្លាប់ហើយ ទើបឲ្យពួកកាដបុរសដាក់ខ្លះនោះចុះមកតាមដីស្អិតបង្ហើមមានខ្លះសន្សឹម ។ ហើយពិនិត្យមើលដោយបំណងថា យើងនឹងចាំមើលដីរ: (ព្រមាន) របស់ចារនោះដែលចេញ ៧ ។ ក៏យើងមិនឃើញដីរ: របស់ចារនោះចេញទៅសោះ ព្រឿងក៏ដែនេះឯងដែលជាហេតុនាំឲ្យខ្ញុំចូលចិត្តថា លោកដទៃគ្មានទេ ។បេ ។

ក្ - បើដូច្នោះ អាត្មាភាពសូមខ្ញុំសួរមហាបពិត្រវិញថា ទ្រង់ធ្លាប់ចូលទៅកាន់ទីព្រះបន្ទូលក្នុងវេលាថ្ងៃ ចានទ្រង់ព្រះសុបិនឃើញសួនច្បារជាទីសប្បាយ ព្រៃជាទីសប្បាយ ទីដែនដីជាទីសប្បាយ ស្រះឈូកជាទីសប្បាយដែរឬទេ ?

ចា - ខ្ញុំធ្លាប់សុបិនឃើញដូចពាក្យព្រះកស្សបដែរ ។

ក្ - ចុះពេលនោះ មានពួកស្ត្រីគមខ្លះ ស្ត្រីតឿខ្លះ ក្មេងស្ត្រីកំពុងពេញលីងខ្លះ ក្មេងស្ត្រីតូចៗខ្លះ ចាំកាន់ព្រះអង្គដែរឬទេ ?

ចា - អើពេលនោះ មានពួកស្ត្រីគមខ្លះ ។បេ ។ ក្មេងស្ត្រីតូចៗខ្លះ ចាំកាន់ខ្ញុំដែរ ។

ក្ - ចុះពួកស្ត្រីទាំងនោះឃើញព្រលឹងរបស់មហាបពិត្រកំពុងចូលមក ឬកំពុងចេញទៅដែរឬទេ ?

ចា - គេមិនឃើញទេ ។

ក - ទ្រកជញ្ញ. អម្ចាស់យ៉ាងពួកស្រីតាំងនោះនៅរស់ត្រឡាំងម្តេច គង់មិនឃើញព្រលឹងរបស់មហាបពិត្រកំពុងរស់នៅ កាលចូលមកឬចេញទៅ ចំណាន់បើមនុស្សស្លាប់ទៅហើយ មហាបពិត្រនឹងគេឃើញព្រលឹងកាលចូលមកឬចេញទៅដូចម្តេចបាន ។ ទ្រកជញ្ញ: បើតាមរឿងក៏ដោយ សូមមហាបពិត្រយុល់ឃើញថា លោកដ្ឋៃមាន ។បេ។ យ៉ាងនេះវិញ ។

ចា - ព្រះកស្សបដ៏ដ្ឋែនពោលយ៉ាងនេះក៏គួរម្ស៉ាងដែរហើយ ប៉ុន្តែខ្ញុំនៅតែចូលចិត្តដូចដើមថា លោកដ្ឋៃគ្មានទេ ។បេ។

ក - ចុះមានរឿងក៏ដោយទៀតដែរឬទេ ?

ចា - មានរឿងក៏ដោយទៀតដែរថា ពួកពាជបុរសក្នុងដ្ឋែនេះចាប់ចោរបានទាំយកមកឲ្យខ្ញុំ ។ ខ្ញុំក៏បង្គាប់ឲ្យពាជបុរសយកដញ្ជ្ជ៉ងថ្ងាងបុរសនេះតាំងរស់ ហើយយកដ្ឋៃបន្ទោះធ្ងចផ្ទ៉ាតរួត មិនឲ្យមានដង្ហ្ម៉ីមចេញចូលតាល់ដ្ឋៃស្លាប់ ។ រួចឲ្យយកដញ្ជ្ជ៉ងមកថ្ងាងម្តងទៀត ។ កាលបុរសនោះនៅរស់ ក៏ជាបុគ្គលស្រាលជាងផង ទន់ជាងផង គួរដល់ការងារជាងផង លុះបុរសនោះស្លាប់ហើយ ក៏ដ្ឋៃជាងទ្ងន់ជាងវិញផង ផ្ទ៉ាងជាងវិញផង មិនគួរដល់ការងារអ្ហ៉ីផង ។ រឿងក៏ដោយនេះឯងជាហេតុនាំឲ្យខ្ញុំចូលចិត្តថា លោកដ្ឋៃគ្មានទេ ។បេ។

(នៅមាត)

ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរថែទួន
ឲ្យបានឆ្ងាប់ខ្ជួន	គង់វង្សគត់មត់
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប.ត.

វិបតានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

ព្រះមហា ម៉ាង ទាត់ រៀបរៀង

អតាវ្ហ្ហិត គុ. ដែលមិនត្រឡប់ ។

អតាវ្ហ្ហិត្ត ស្ត្រី. ការមិនត្រឡប់មកកើតទៀត ។

អតាវ្ហ្ហត គុ. ដែលមិនបិទបាំង, ដែលមិនស្ទៀកពាក់ ។ **អតាវ្ហ្ហតាគិល**

(**អត៊+អាវ្ហ្ហត+អគិល**, គុ. (ឡារ) ដែលមិនមានប្រេះ។

អតាវ្ហ្ហិប្ត ស្ត្រី. ការមិនភ្ជៀង, ការរាំងភ្ជៀង, អំណត់ភ្ជៀង ។

អតាគ គុ. (**អត៊+អាគ**) ដែលមិនមានសង្ឃឹម ។

អតាគ បុំ. **អ+តាគ** ការមិនវិនាស ។

អតាគក នបុំ. (**អត៊+អាគក**) ការមិនបរិភោគ, ការអត់បាយ, អំណត់។

អតាគកាយន នបុំ. ការមិនបរិភោគ ។

អនាគាស្យ គុ. ដែលមិនគប្បីដិកដិស្ថើមចូល ។

អនាកិត គុ. ដែលឃ្លាន ។ អនាកិត្ត នបុំ. កិរិយាមិនបរិភោគ, ការមិន
បរិភោគ ។

អនាកិនិ គុ. ដែលមិនរិនាស ។ គុណនាមនៃបរមាត្មន ។

អនាក្រៃ គុ. ដែលមិនស្តាប់បង្គាប់, ដែលថ្លង់ ។

អនាក្រិត គុ. ដែលមិនអាស្រ័យនឹងគេ, ដែលឯកភាឡ ។

អនាគ្ទាម្ម ការលមិនបរិភោគ ។.

អនាច្ឆ្ត គុ. ដែលមិនមានភ័យ ។

អនាសង្ត បុំ. ការមិនជាប់, ការមិនទើសទាក់, ការមិនអាល័យ ។

អនាសភ្យ គុ. ដែលមិនឈ្មោះថាអាសរៃ ។

អនាសាទិត គុ. ដែលមិនតៅ, ដែលមិនតាំងតៅ, ដែលមិនបាន ។

អនាសាទ្យ គុ. ដែលមិនគប្បីចូលទៅបាន, ដែលមិនគប្បីយល់បាន ។

អនាស្ថិក គុ. ដែលយល់ថាមិនមាន, ដែលមិនឈ្នៀ, ដែលមិនកាន់សាសនា,

អនាស្ថិក្យ នបុំ. ការយល់ថាមិនមាន, ការមិនឈ្នៀ
ការមិនកាន់សាសនា ។

អនាស្ថីណ គុ. ដែលមិនក្រុសាម, ដែលមិនស្ទៀកតាក់, ដែលអាត្រាត ។

អនាស្ត ត្ថ ដែលមិនពាំងនៅ, ដែលត្រដើយកន្លើយ, ដែលមិនគោរព ។

អនាស្ថា ស្ត្រី. ការមិនពាំងនៅ, ការត្រដើយកន្លើយ, ការមិនគោរព ។

អនាស្ថិត ត្ថ ដែលមិនបិតនៅ ។

អនាស្វាទ បុំ. ការមិនបរិភោគ, ការសោះកញ្ច្រោះ ។

អនាស្វាទិត ត្ថ. ដែលមិនបរិភោគ, ដែលមិនមានរសជាតិ ។

អនាហត ត្ថ. ដែលមិនវាយ, ដែលមិនបៀតបៀន, ដែលមិនដេញដំ (ត្រឿង
ឧបករណ៍ភ្លេង) ។ - តាទ, បុំ. មានសំឡេងលាន់ឮ គឺបុគ្គល
មិនវាយហើយ ។

អនាហារ ត្ថ. ដែលមិនបរិភោគអាហារ, ដែលអត់អាហារ, បុំ. ការមិនបរិ-
ភោគអាហារ, ការអត់អាហារ, ការមិនបានផលិតផល ។

អនាហារិនី ត្ថ. អ្នកមិនបរិភោគអាហារ ។

អនាហាយិ ត្ថ. ដែលមិនគប្បីបរិភោគអាហារ, ដែលមិនគប្បីផលិត ។

អនាហិតាគ្និ ត្ថ. ដែលមានត្រះអគ្និ (ត្រះគ្ឆ្លាធាន គឺ . . . មិនរក្សាហើយ ។
- តា ស្ត្រី. ភាវនៃត្រះអគ្និ គឺ . . . មិនរក្សាហើយ ។

អនាហុត ត្ថ. ដែលមិនបូជាហើយ ។

វត្តព្រះពុទ្ធសាសនាខ្មែរ

នៅខេត្តមាត់ជ្រូកកម្ពុជាក្រោម

លោក ឌឹក គាម រៀបរៀង

អត្ថបទដ៏ខ្លីនេះ ទុកគ្រាន់ជាឯកសារសំរាប់ឲ្យខេមរជាតិទឹករលឹកនូវអនុស្សាវរីយ៍នៃអារាមរបស់ខ្មែរ ក្នុងខេត្តមាត់ជ្រូកនៅកម្ពុជាក្រោម ។ ទុកជារឿងនេះខ្លីក៏ដោយ ក៏អាចផ្តល់នូវឯកសារសំខាន់មួយដល់ជាតិខ្មែរយើងដែរ ។ ខ្ញុំចង់ឲ្យអ្នកអានជ្រាបច្បាស់នូវប្រវត្តិការនៃវត្តទាំងនោះដែរ តែលើកដំបូងនេះ ខ្ញុំសូមជូនប្រវត្តិសង្ខេបនៃនាមវត្តខ្លះ ៗ សិន ។ បើសិនជានៅខ្វះត្រង់ណា សូមលោកអ្នកអានដែលចេះចាំមេត្តាជួយបំពេញឲ្យបានផង ។

(ស្រុកស្វាយទង ហៅ ទ្រីតុង)

អារាមដែលនៅជុំវិញភ្នំទ្វារ

១- វត្តស្វាយទង (មហានិកាយ) វត្តនេះតាមពាក្យអ្នកស្រុកឲ្យការថា វត្តនេះពីដើម គេហៅថាវត្តស្វាតោង ។ តែក្រោយមកក៏អានទៅជាស្វាយទងទៅវិញ ។ វត្តស្វាយទងនៅក្នុងឃុំស្វាយទង ឃុំទ្រីតុង តាមឧបាសក ហែម គាត់ចាំថា[1] ចៅអធិការដែលគាត់ស្គាល់មានដូចតទៅនេះគឺ :

---

១) តាមពាក្យមានលោកតា ហែម រស់ក្នុង នៅឃុំស្វាយទងអាយុ ៧៦ ឆ្នាំ ប្រាប់ខ្ញុំផ្ទាល់ ។

ឆៅអធិការ	ពៅ	ឆៅអធិការ	ត្រែង
"	អុក	"	ឡូង
"	ទេព	"	លឹម

២. វត្ត្រៃវែង (ធម្មយុត្តិ) នៅក្នុងឃុំត្រីតុង ចម្ងាយប្រហែលកន្ទះគ៉ឡូញ៉ាវត្តស្វាយទង ។

៣. វត្ត្រតាប៉ា (មហានិកាយ) នៅឃុំត្រីតុង ។ វត្តនេះបានជាមានឈ្មោះដូច្នេះ ព្រោះលោកតា "ប៉ា" ជាអ្នកផ្តើមកសាងវត្តនេះ នៅលើក្នុំមួយកំពស់ប្រហែលក្នុំបាក់ទៃងចម្ងាយប្រហែល ១ គ៉ឡូកន្ទះពីផ្សារស្វាយទង។ លុះដល់ការកសាងអាពាមនេះបានរួចស្រេចហើយ លោតាប៉ា ក៏បានតែងតាំងឡើងធ្វើជាឆៅអធិការមុនគេ ហើយនាមវត្តក៏ជាប់រហូតមកដល់សព្វថ្ងៃនេះ ។

៤. វត្ត្រគោកត្រែង (មហានិកាយ) នៅឃុំត្រីតុង ។ វត្តនេះសង់នៅក្បែរបឹងមួយ កាលពីដើមមានសុទ្ធតែដើមត្រែង ។ ដល់ក្រោយមកបឹងនេះគោកទឹកទៅ គេឲ្យឈ្មោះថា គោកត្រែង ហើយវត្តក៏ឲ្យឈ្មោះទៅតាមហេតុនោះទៅ ។

៥. វត្ត្រជ្រោះពក (មហានិកាយ) នៅភូមិជ្រោះពក ឃុំស្តេចទឹក(១)

---

១) តាមអ្នកទ្ធះហៅថា ឃុំដាច់ទឹក ។

សត្វថ្ងៃហៅឃុំអាងទឹក ។ វត្តនេះសង់នៅកែ្សរជ្រោះដែលបរិបូណ៌ទៅ ដោយដើមឫស្សីពក ។ ការឲ្យនាមវត្តនេះ ទៅតាមគេទៅនៃវត្តដែលសង់នៅក្នុងភូមិជ្រោះពកផង ហើយតាមកន្ទ្ធ ១ ដែលមានឫស្សីពកច្រើនផង ។

៦ - វត្តស្វាយតាហង្ស (មហានិកាយ) នៅភូមិស្វាដាម ឃុំស្ពោចទឹក (អាងទឹក) ។ វត្តនេះជាដីកម្ម្ពីរបស់លោកតាស្វាយនិងលោកតាហង្ស ជាម្ចាស់ដី ដែលបានប្រគេនដីនេះទៅព្រះសង្ឆឲ្យគេធ្វើជាវត្ត ។ ការកសាងបានជាអាចមហើយ គេសន្ធ្ងន់ឲ្យនាមតាមម្ចាស់ដីថា វត្តស្វាយតាហង្ស ។ មានលោកអ្នកខ្លះបន្ថែមថា វត្តនេះគឺជាចំការស្វាយរបស់តាហង្ស ។ តាមលោកតាហែមថា គឺម្ចាស់ដីពីរនាក់ឈ្មោះតាស្វាយនិងតាហង្ស(១) ។ មានទ្ធ ១ សក-សិកាភាគច្រើនដែលបានកត់ត្រាការកសាងវត្តថា ជាដីរបស់តាស្វាយនិងតាហង្ស ។ វត្តស្វាយតាហង្សស្ថាបនាមិនយូរប៉ុន្មានទេ ហើយមានចៅអធិការដូចតទៅ

១ - ចៅអធិការព្រះនាម ហែម ៣ - ចៅអធិការព្រះនាម ឆុន

២ - " ភី ៤ - " ឃុត

៧ - វត្តត្រពាំងត្រាវ (មហានិកាយ) នៅភូមិត្រពាំងត្រាវ ឃុំស្ពោចទឹក (អាងទឹក) ។ ន័យរបស់អាចមនេះ ប្រហែលជាគេឲ្យទៅតាម

---

១) ពត៌មាននេះ លោក ៣ ហែម ជាបណ្ណកិរ៉ា ម្ចាស់ពីរនាក់ ៖ តាស្វាយនិងតាហង្ស ។

ស ណ្ណានេះ ទ ស ភាគ នៃ ត្រ ពាំ ង ដែ ល គេ ដាំ ត្រាវ ។ ប្តូ ក ឈ្ម ោ ះ ទៅ តាម ភូ មិ ដែ ល ឈ្ម ោ ះ ថា ភូ មិ ត្រ ពាំ ង ត្រាវ ។ ទៅ អ ធិ ការ ដែ ល អ្ន ក ឲ្យ ការ ចាំ គឺ ៖

ទៅ អ ធិ ការ ម្ន ។ ទៅ អ ធិ ការ អ ុ ក

" អ្ន ន " ស ្ន ដ

ទៅ អ ធិ ការ មុ ន នេ ះ ទ ៀ ត មិ ន ចាំ ទេ ។

៨ - វ ត្ត ស្ន ាយ ដ ង្គ ុ (ម ហា ន ិ ក ាយ) ភូ មិ ស្ន ាយ ដ ង្គ ុ ឃ ុ ំ ស្ត េ ច ទ ឹ ក (អ ាង ទ ឹ ក) ។

៩ . វ ត្ត ស ម ស ីហ ៍ (ម ហា ន ិ ក ាយ) ទ ៅ ឃ ុ ំ អ ូ រ ធ ំ យ ួ ន ហ ៅ (អ ូ រ ឡ ឹ ម)

១០ . វ ត្ត ក ំ ភ ្ល ឹ ង (ម ហា ន ិ ក ាយ) ទ ៅ ឃ ុ ំ អ ូ រ ធ ំ (អ ូ រ ឡ ឹ ម)

១១ . វ ត្ត ស្ត ្រ ៃ ប ឹ ង (ម ហា ន ិ ក ាយ) ភូ មិ ស្ត ្រ ៃ ប ឹ ង ។

១២ . វ ត្ត ព ្រ ះ ជ ាត ុ (ម ហា ន ិ ក ាយ) ។ ក ន្ល ែ ង ដ ែ ល ព ្ន ាត ់ ន េ ះ ហ ើ យ ដ ែ ល គ េ ប ាញ ់ អ ាចារ ្ យ ស ្ន ាញ ់ ន ៅ ល ើ ធ ្ម ម ព ្រ ះ ว ิ ห ារ ទ ម ្ម ាក ់ ស ្ន ាប ់ ន ៅ ល ើ ដ ី ។

១៣ - វ ត្ត ត ្ន ោ ត ជ ្រ ុ ំ (ម ហា ន ិ ក ាយ) ទ ៅ ឃ ុ ំ ខ ្ន ុ រ យ ួ ន ហ ៅ ក ូ ត ូ ។ វ ត្ត ន េ ះ ឲ ្យ ឈ ្ម ោ ះ ទ ៅ តា ម ស ្ថ ាន ក ន ្ល ែ ង ដ ែ ល ម ាន ត ្ន ោ ត ដ ុ ះ ជ ុ ំ គ ្ន ា ។

១៤ - វ ត្ត ទ ួ ល ត ាម ុ ង (ម ហា ន ិ ក ាយ) (ខ ្ញ ុ ះ ថ ា វ ត្ត ទ ួ ល ដ ាម ុ ង) ទ ៅ ក ន ្ល ែ ង ឃ ុ ំ ខ ្ន ុ រ [1] (ក ូ ត ូ) ស ង ់ ន ៅ ល ើ ទ ួ ល ម ួ យ ត ូ ច ។ វ ត្ត ន េ ះ ប ្រ ហ ែ ល ជ ា គ េ

---

1) ក្លាយ មក សត្វ ថ្ម ៃ ហ ៅ ว่า ក ូ ត ូ ។

ឲ្យឈ្មោះតាមអ្នកដែលបានទៅនៅទ្ធលនេះមុនគេ (?) ។

១៥ - វិត្ត្រាក (មហានិកាយ) នៅឃុំខ្ទោរ (កូតូ) សង់នៅលើ ទ្ធល ១ ភូច ដែលគេយកឈ្មោះតាមដើមឈើត្រាកមួយដើម ។

១៦ - វិត្តខ្ទោរលើ (មហានិកាយ) នៅឃុំខ្ទោរ ។ វត្តនេះឲ្យ ឈ្មោះទៅតាមភិនភាគឃុំ នឹងដើមខ្ទោរ ។ សព្វថ្ងៃគ្មានព្រះសង្ឆពុទ្ធ-សាសនិកហីនយានទេ ។

១៧ - វិត្តប្រាសាទផុះ (មហានិកាយ) នៅឃុំខ្ទោរ ។ វត្តនេះ ពីដើមឈ្មោះថាវត្តពញ ។ ហេតុដែលឲ្យមានការកជាវត្តនេះទ្បើង ព្រោះ ព្រះសង្ឆនៅវត្តខ្ទោរមានបដិបក្សទាស់ទែងគ្នា ។ ព្រះសង្ឆបែកបាក់គ្នា ក៏ចញពីវត្តខ្ទោរមកកវត្តនេះ ឲ្យឈ្មោះថាវត្តពញ តែក្រោយមកក៏កែ ឈ្មោះថា វត្តប្រាសាទផុះ ប្រហែលជាង ២០ ឆ្នាំមុននេះ ។

១៨ - វិត្តពោធិទាប (មហានិកាយ) ក្នុងឃុំខ្ទោរ ព្រោះមានដើម ពោធិមួយដើមទាប ជុះនៅមុខវត្ត ។

១៩ - វិត្តស្ទាយស (ធម្មយុត្តិ) នៅឃុំខ្ទោរ ។ ឈ្មោះវត្តនេះ តាម អ្នកខ្លះថាឲ្យឈ្មោះតាមគេទដើមស្ទាយដែលមានសម្បូរស ខ្លះថាជាកន្ទែង ដើមស្ទាយរបស់តាស ។

អារាមដែលនៅជុំវិញភ្នំក្រសាំង

២០- វត្តភ្នំពីរលើ (ធម្មយុត្តិ) នៅឃុំភ្នំពីរ (ឃុំខ្ទះហៅថា ណាមយ៉ូ) សាងក្បែរជើងភ្នំក្រសាំង ។

២១- វត្តភ្នំពីរកណ្ដាល (ធម្មយុត្តិ) នៅឃុំភ្នំពីរ (ណាមយ៉ូ) កសាងក្បែរជើងភ្នំក្រសាំង ។

២២- វត្តភ្នំពីរក្រោម (ធម្មយុត្តិ) នៅឃុំភ្នំពីរ ណាមយ៉ូ នៅក្បែរជើងភ្នំក្រសាំង ។

២៣- វត្តក្រាំងក្រូច (មហានិកាយ) នៅឃុំលាំង ចុងឡាំង នៅចម្ងាយប្រហែលពីរគីឡូពីភ្នំក្រសាំង ។

២៤- វត្តកូលកាស (ធម្មយុត្តិ) នៅឃុំលាំង ។ សង់នៅលើទួលមួយតូច ។

២៥- វត្តក្រាំង នៅឃុំលាំង ។ វត្តនេះពីដើមជាវត្តធម្មយុត្តិ ក្រោយមកវត្តនេះក៏បានមកជាសម្បត្តិព្រះសង្ឃគណៈមហានិកាយ ដល់ក្រោយមកទៀតវត្តក្រាំង ទៅជាវត្តធម្មយុត្តិទៅវិញ ។ ការបែរបេរផ្ទេរគ្នាទៅវិញទៅមករវាងព្រះសង្ឃធម្មយុត្តិនិងមហានិកាយ នៅទីបំផុតសព្វថ្ងៃនេះ ក៏បានទៅជាសម្បត្តិអាមេរិកាំងដាក់កងទ័ពទៅវិញ ។

២៦- វត្តពង្រ (មហានិកាយ) នៅឃុំលាំង ភូមិស្រឡង ។

២៧-វិត្តសាឡូង (ធម្មយុត្ត) នៅយុំលឿនកី ។ នៅក្បែរដើន
ក្នំតូចស្រឡូន ។

២៨-វិត្តទំពូងលើ (មហានិកាយ) នៅយុំលឿនពី

២៩-វិត្តទំពូងក្រោម (មហានិកាយ) នៅកូមិទំពូន យុំ
លឿនពី ។

៣០-វិត្តគោករមៀត (មហានិកាយ) នៅកូមិគោករមៀត យុំ
លឿនកី ។

៣១-វិត្តស្វាតាណិប (មហានិកាយ) នៅកូមិគោករមៀត យុំ
លឿនកី ។ លោកតាណិបបានយកកូមិស្វាយតាត់ប្រគេនម្រះសង្ឆ ហើយ
តាត់ប្ជសជាកិកូត្ថុនព្រះពុទ្ធសាសនា ហើយធ្វើជាវៅអធិការវត្តនោះផន ។

៣២-វិត្តអណ្ណូងប៉ែន (មហានិកាយ) យុំអណ្ណូនប៉ែន (បាជុក) ។

៣៣-វិត្តអង្ក (មហានិកាយ) យុំអណ្ណូនប៉ែន ។

៣៤-វិត្តប្លឹង (មហានិកាយ) កូមិថ្នាក់ យុំឡេត្រី ។

៣៥-វិត្តអណ្ណូងឬរ (មហានិកាយ) នៅកូមិពពាយស្វាយ យុំ
ឡេត្រី ។

អារាមដែលនៅជុំវិញក្នុំពពាល

៣៦ - វិត្ត អំពាយស្វាយ (មហានិកាយ) នៅកូមិពពាយស្វាយ ឃុំឡេត្រ ។ វត្តនេះឲ្យឈ្មោះទៅតាមកូមិដែលជាកន្ទែងកសាងវត្ត ។

៣៧ - វិត្ត ត (មហានិកាយ) កូមិសង្កែជួប ឃុំធៀតណាប ។

៣៨ - វិត្ត សង្កែមាស (មហានិកាយ) កូមិសង្កែមាស ឃុំធៀបណាប ។

៣៩ - វិត្ត ពោធិតុង (ធម្មយុត្តិ) នៅឃុំធៀតណាប ។ តាតុងជាំដើមពោធិមួយដើម ហើយតាត់កសាងធ្វើជាវត្តឡើង ។

៤០ - វិត្ត ត្នោត (ធម្មយុត្តិ) នៅកូមិដើងគោ ឃុំធៀតណាប ឲ្យឈ្មោះតាមកិនកាតមានដើមត្នោត ។

៤១ - វិត្ត ត្រពាំងអណ្ត្ងង (ធម្មយុត្តិ) កូមិដើងគោ ឃុំធៀតណាប ។

៤២ - វិត្ត ស្វាយបេក (ធម្មយុត្តិ) កូមិស្វាយបេក ឃុំធៀតណាប ។

៤៣ - វិត្ត បារឹក (ធម្មយុត្តិ) កូមិគោល ឃុំធៀតណាប ។

៤៤ - វិត្ត ដើមផ្ទោក (មហានិកាយ) នៅកូមិដើមផ្ទោប ឃុំធៀតណាម ។

៤៥ - វិត្ត សុពណ៌លើក (ធម្មយុត្តិ) នៅឃុំវិញត្រុង ។ វត្តនេះកសាងដោយទកញ៉ា លិមហាក់សេង ។

៤៦-វិត្តធម្មនិមិត្ត ធម្មយុត្ត៖) ភូមិជីទក ឃុំនិញត្រុន ។

៤៧-វិត្តជីទត (មហានិកាយ) ឃំទូតែ ។

៤៨-វិត្តប្រឡាយមាស (មហានិកាយ) ភូមិប្រឡាយមាស ឃុំទូតែ ។ វត្តនេះឲ្យឈ្មោះទៅតាមភូមិដែលជាកន្លែងកសាងអាវាម ។

៤៩-វិត្តក្រាំងបាយ (មហានិកាយ) ភូមិក្រាំងបាយ ឃុំទូតែ ។

៥០-វិត្តស្វាយតាសម (មហានិកាយ) ភូមិស្វាយតាសម ឃុំត្រាក់ទ្វាន ។

៥១ វិត្តគោកវំដែល (មហានិកាយ) ភូមិគោកវំដែល ឃុំត្រាក់ទ្វាន ។

៥២-វិត្តទឹកផុស (មហានិកាយ) ភូមិប្រាក់ ឃុំតាជាញ់ ។

៥៣-វិត្តជីក្អេង (រំដ្ឋលទ្ឋលសុរកី) ភូមិជីក្អេង ឃុំតាជាញ់ ។

ស្រុកក្រាទៅ (ធិញបៀង)

៥៤-វិត្តព្រាល (មហានិកាយ) ភូមិព្រាល ឃុំអៀងតី ។

៥៥-វិត្តទ្លាទ្ទារ (មហានិកាយ) ភូមិទ្ទាទ្ទារ ឃុំអៀងតី ។

៥៦-វិត្តរោហ៍ (មហានិកាយ) ភូមិរោហ៍ ឃុំអៀងតី ។

៥៧ - វិត្តណៃងណង (មហានិកាយ) ជាវត្តថ្មីនៅទាងគែតកុំ
ពោហ៍ ឃុំអៀងតឹ ។

៥៨ - វិត្តទឹកល្អក់ (មហានិកាយ) ជាវត្តថ្មី នៅឃុំអៀងតឹ ។

៥៩ - វិត្តត្រពាំងជ្រៅ (ធម្មយុត្តិ) នៅឃុំក៉ន់យ៉ាង ។

·សាសន៍ "តាំរ" នៅក្នុងឃុំបាក់គ្រាំងមានតែ ៤ ភូមិទេ គឺភូមិឪឡឹក; ភូមិព្រាល, ភូមិស្ពង់, ទីងភូមិខ្វារ ។ ក្នុងភូមិនីមួយ ៗ ទាំងប្រុសទាំងស្រីមានប្រហែលជាង ១០០ នាក់ប៉ុណ្ណោះ ។

-ឥឡូវនេះបន្តដំណើរទៅកំពង់ប្រណាកទៀត ពីរវៀងទៅកំពង់ប្រណាកមានចម្ងាយ ៦៩គ.ម ។ ចេញពីរវៀងបានប្រហែល ៣គ ម.

មានផ្លូវបែកជាពីរ   គឺខាងឆ្វេងទៅកំពង់ប្រណាក ខាងស្ដាំទៅកំពង់ព្រៅ ទៅឆែប អតីតខេត្តម្លូព្រៃ) ។

មុននឹងចូលទៅកំពង់ប្រណាក, ខ្ញុំចង់ឲ្យមិត្ត, មិត្តនារីទាំងឡាយ ស្គាល់អូរមួយសិនហៅថា "អូរស្វាយកួង" អូរស្វាយបាយ ។ នៅក្បែរអូរស្វាយកួង នេះមានត្រពាំងមួយហៅថា «ត្រពាំងប៉ង់តាទីប» ពាក្យថា "ប៉ង់" ប្រែថា «ប្រឡោះស្នា» ជាភាសាព័រ, ខៃសេចក្ដីថា : ត្រពាំងហ្នឹងឯង ដែលតាទីបជាមេឃុំលោក ត្រូវព្រួញមួយប្រឡោះស្នារបស់តាកែវមេឃុំ ធ្លាក់ក្ដោង ស្លាប់ដួលដេកនៅទីនោះ មានរូបសំណាករហូតសព្វថ្ងៃ, ចម្ងាយប្រហែល ២០ គ.ម ពីសាលាស្រុករវៀងផ្នែកខាងទិសឧត្តរ ។

រឿងដើម

មានមន្ត្រីឃុំពីរនាក់ ម្នាក់ឈ្មោះតាទីប, ម្នាក់ទៀតឈ្មោះតាកែវ ។ មេឃុំទាំងពីរនាក់នេះ នៅក្រោមអាណាព្យាបាលប្រមុខខេត្ត ជូ ម៉ឺង ហៅ ហ្វាយខេត្តម្លូព្រៃ (ឆែបនាបច្ចុប្បន្ន) ។ អ្នកទាំងពីរនាក់មានការតាស៊ូទែង ខ្វែងគំនិតដណ្ដើមកូនឃុំគ្នា ដោយអាងថាមានពស្ត្រច្រើនតែសព្វខ្លួន រហូតដល់ទៅមានកោលាហល កេណ្ឌពស្ត្រចូលប្រយុទ្ធច្បាំងកាប់សម្លាប់គ្នា យ៉ាងមហាសាហាវ ស្លាប់ពប់រយនាក់ នៅទីសមរភូមិ ដោយសារមេបះបោរ ទាំងពីរនាក់នោះនាំបង្ក ។ រឿងនេះដឹងដល់លោកប្រមុខខេត្តម្លូព្រៃភ្លាម លោកក៏អញ្ជើញមកបានកោះហៅមេបះបោរទាំងពីរនេះ មកដន្ទុំដះគា

សេចក្ដីឲ្យ គឺលោកចែកកស្ត្រឲ្យបានស្មើ ៗ គ្នា តែមេបះទាំងពីរនេះ ពុំសុខចិត្តទាំងកូនឃុំក៏ពុំចិត្តទៀត ៗ រឿងនេះធ្វើឲ្យលោកប្រមុខខេត្តខ្វល់ យ៉ាងក្រៃលែង ៗ ហើយក្រោយមកលោកក៏ប្រើមធ្យោបាយផ្សេងទៀត ដោយបួងសួងព្រះឥន្ទ្រទិព្វចក្ខុ ជាអ្នករកយុត្តិធម៌ឲ្យគឺតម្រូវឲ្យផ្សងទឹងស្នា ៗ បើមេឃុំទាំងពីរនេះណាមួយចិត្តពុំស្មោះត្រង់ , ទុច្ចរិត , ល្មោភលោភលន់ ឲ្យត្រូវទឹងព្រួញស្នាស្លាប់ឲ្យបានប្រចក្សទឹងភ្នែក ៗ កូនក្រស្តទឹងមេឃុំក៏ សុខចិត្តទទួលព្រម ឲ្យតែបានឃើញនូវពិតនូវយុត្តិធម៌ ៗ

លុះព្រឹកឡើងប្រមុខខេត្តម្លូព្រៃ ក៏ចាប់ផ្ដើមធ្វើពិធីរកយុត្តិធម៌ឲ្យមេបះ បោះទាំងពីរ ៗ លោកបានឲ្យឈរតាមក្រុម គឺក្រុមមេឃុំទិបឈរមួយក្រុម ៗ ក្រុមមេឃុំកែវ ឈរមួយក្រុម ក្បែរអូរមួយ ៗ រីឯមេឃុំទាំងពីរ លោកប្រមុខខេត្តបានឲ្យឈរ ចំកណ្ដាលក្រុម ចំមុខស្នាទាំងពីរដែលមានព្រួញយ៉ាងស្រួចប្រកបដោយជ័រឆក់ ៗ ស្នាទាំងពីរនេះមួយរបស់មេឃុំកែវ , ១ទៀត របស់មេឃុំទិប ៗ លោកប្រមុខខេត្តបានចាប់យឹតស្នាដោយខ្សែងងីរចងដាក់ ព្រួញ ហើយតម្កល់ លើជើងពានប្រាក់ពីរយ៉ាងធំ តម្រង់ចំកណ្ដាល ដើមទ្រូង មេបះបោះទាំងពីរនេះ ៗ បន្ទាប់មកលោកក៏លើកដៃប្រណម្យ ឡើងចាប់ថ្លែងប្រកាសបួងសួងសំបូងសំរូងយ៉ាងខ្លាំង ៗ ដូចតទៅ :

«នៅក្នុងពិធី អរុណោទ័យស្មើដំពេញពន្លឺនេះ ក្នុងឋាន ខ្ញុំជាប្រមុខ ដែនដីម្លូព្រៃ ទីងជាប្រមុខយុត្តិធម៌ ខ្ញុំសូមយាងព្រះឥន្ទ្រភ្នែកទិព្វ ត្រចៀក

ទិព្វដ៏មានឫទ្ធិអនេកអនន្តប្រកបក្សេត្រប្រសិទ្ធិជ័យ ដល់ស្នាតាំងពីរនេះ ថាបើតាកែវមេឃុំលោភ សុំស្នាតាទីបឲ្យយុត្តិធម៌ បើតាទីបជាមេឃុំលោភ សុំស្នាតាកែវឲ្យយុត្តិធម៌ ក្នុងកណ្ដាលវៀណរង្គនេះ ដើម្បីឲ្យពស្ត្របាន ជាក់ស្តែងទាន់ហន់ ក្នុងគ្រាឥឡូវ សូមព្រះអង្គប្រទានយុត្តិធម៌ ។ ! »

គួរឲ្យអស្ចារ្យណាស់ ! គ្រាន់តែគប់វា ៣ ដងភ្លាម កែវស្នាក៏ហោះ ផាំងដោយឯកឯង ព្រួញដ៏មុតក៏ស្ទុះទៅដោតចំកណ្ដាលទ្រូងតាស៊ូរពេប ។ ក្រុមយុត្តិធម៌ ក៏ស្រែកហ៊ោ ជយោ ! ជយោ ! យ៉ាងកងរំពង ៗ អនិច្ចា! តាទីបនាមេឃុំលោភ ដោយត្រូវដំរងក់ ក៏ប្រកាច់ដួលដេកនៅទីនោះភ្លាមៗ តែមុននឹងគាត់ស្លាប់ គាត់បានសារភាពចំពោះលោកប្រមុខខេត្តថា ៖ គាត់ជាមនុស្សល្មោភ ហើយថែមទាំងជាមនុស្សអយុត្តិធម៌ទៀតផង តែគេជាមនុស្សល្អ ស្មោះត្រង់នឹងផែនដី មិនលោភ សូមព្រះតេជព្រះគុណជាប្រមុខយុត្តិធម៌ ឆ្លាក់រូបខ្ញុំបាទមួយទុកជាកេរ្ដិ៍ដំណែល ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា :

«នេះហើយរូបតាទីប ជាមេឃុំល្មោភ ត្រូវព្រួញយុត្តិធម៌»

ថាហើយគាត់ក៏ដាច់ខ្យល់ស្លាប់ក្នុងខណៈនោះភ្លាម ។

រីឯតាទីបខាងខ្មោចមេឃុំលោភនេះ និមិត្តតែឃើញទៅហ្វាយខ្លួន ដួលស្លាប់ភ្លាម បះសក់ព្រឺងរត់យកតែព្រះអាយុ តែសត្វខ្លួន ខ្លាចព្រួញយុត្តិធម៌ទាញ់ នាំគ្នារត់ពោលបាយ ដែលនាំប្រុងបរិភោគក្បែរអ្នក ។

គាំងពីមានហេតុដូចពណ៌នា ខាងលើនេះមក ទើបបានជាសាសន៍ពារ៍ គេដាក់នាមអូរនោះថា "អូរស្ពាយកូន" ប្រែថា "អូរស្ពាយបាយ" រហូតសព្វថ្ងៃ ។

ឯរូបសំណាក គាត់ទើបត្រូវព្រួញចំកណ្ដាលទ្រូង ក៏មានរហូតមកដល់សព្វថ្ងៃនេះដែរ ។ រូបនេះជាសក្ខីភាព នៃអំពើលោភរបស់គាត់ផងទីផង ជាគោលគំនិតដ៏សំរើកមួយសំរាប់ប្រជាពលរដ្ឋខ្មែរយើងទូទៅ ពិចារណាកង់ធាតុជីវិតផង ។

គួរឲ្យកត់សំគាល់ ៖

ប្រជាជនភាគខាងជើងនេះ មានចិត្តស្មោះត្រង់នឹងគ្នាណាស់ មិនចេះប្រវ័ញ្ច បោកប្រាស់ឬកុតករឡើយ ហើយជាពិសេសទៀត តែមនុស្សណាវៀចគ្មានសច្ចៈដើរព្រៃមិនបាន "ខ្លាខាំស៊ីតាំងកណ្ដាលថ្ងៃ" ៗ ដូច្នោះហើយ ទើបតាំងប្រុសតាំងស្រី ក្មេង ចាស់ គេនិយមតែពាក្យសច្ចៈពាក្យសត្យ ព្រោះខ្លានៅតំបន់នោះច្រើនណាស់ ហើយមានច្រើនជាងខេត្តដទៃផង ។ កាលណាមានខ្លាស៊ីនរណាម្នាក់គេថា "ខ្លាអ្នកសច្ចំស៊ីហើយ" ព្រោះខុសមាត់និយាយពុំត្រង់ ។

គឺនេះ សុំទាញអារម្មណ៍លោកអ្នកមកផ្លូវថ្មី ខាងឆ្វេងវិញ គឺផ្លូវទៅខេត្តថ្មី (កំពង់ប្រណាក) ផ្លូវនេះអាចទៅបានតែរដូវប្រាំង ឯរដូវវស្សា

នៅមិនរួចទេ ព្រោះទីនេះជាទីទំនាប មានអូរច្រើន ហើយទឹកនៅជោក ជាំពាសវាលផង ។

បន្ទាប់ពីទស្សនីយភាព ដីសែនត្រជាក់, កាត់វាល, ឆ្លងអូរ ចូលព្រៃ ដីសែនស្កុក, ព្រៃឫស្សី, ព្រៃត្បែងដុះហូរហែតាមជងផ្លូវ ភូមិគោកអំពិលខាងឆ្វេងដៃ ។ មួយស្របក់ទៀតដល់ភូមិព្រាលនៅខាងស្តាំដៃ តែភូមិនេះនៅឆ្ងាយពីថ្នល់បន្តិច ។ ជួនកាលខ្លះ មានក្មេងជំទង់ ៗ ដាក់ទឹកត្នោតព្យួរនៅដើមឈើ ក្បែរផ្លូវសំរាប់លក់ចែកដល់អ្នកធ្វើដំណើរ ។ ពេលមួយខ្ញុំឲ្យបររថយន្តឈប់ក្បែរបំពង់ទឹកត្នោត ហើយសួរថា : « មួយបំពង់ថ្លៃប៉ុន្មានប្អូនប្រុស ? » គេធ្វើមុខញញឹមហើយឆ្លើយថា : « ៣ រេល »

– ២ រៀលបានទេប្អូន? ស្រាប់តែ ឆ្លើយថា: "មិនខ្ចីលក់សោះឡើយ" ។ ពាក្យនេះបើខ្មែរកណ្តាលយើងនិយាយ . គេចាប់ថ្នាក់យើងប្រឡាមខាម មិនខានតែខាងដំបន់នេះ ជាទំនៀមទម្លាប់គេនិយាយតែអ៊ីចឹង ។ ដោយខ្ញុំចង់ស្តាប់សំដីនឹងនិយាយលេង ឲ្យបានច្រើន ខ្ញុំក៏អង្វរថា "ឲ្យតែ ២រ" តែគេតបមកវិញថា: « មិនគិតជាលក់សោះឡើយ » ។ ដូច្នេះសុំជំរាបថា ប្រជាពលរដ្ឋនៅនេះ តែគេសំរេចថាលក់ប៉ុន្មើអ៊ី ៗ យ៉ាងម៉េចគឺអ៊ីចឹង ពុំសូវមានប្រែប្រួលទេ ។

តទៅទៀតភូមិក្រាំងដូង ផុតពីភូមិនេះដល់ត្រង់គោលមួយ លោក

អ្នកក្រឡេកទៅខាងជើង នឹងឃើញភ្នំមួយខ្ពស់ត្រដែត ដែលរុក្ខជាតិធំៗ ខាន់ខាប់ដុះអមដាបពេក នឹងផ្ទាំងថ្មសិលាចាំងផ្លេកៗ ហាក់បីដូចគេយកកញ្ចក់ទៅពាយនៅទីនោះ ភ្នំហ្នឹងហើយដែលជីដូនជីតាយើងធ្លាប់និយាយថា: « កទីពកើតនៅភ្នំត្បែងហើយ ស្រុកយើងនឹងសុខសប្បាយ » នេះហើយភ្នំត្បែងៗ ខាងមុខបន្តិចទៀតលោកអ្នក មិត្រ មិត្រនារីទាំងឡាយ នឹងពុំបានឃើញពន្លឺថ្ងៃទេ ព្រោះម្លប់ហូតជាប់ជាង ២០ គ.ម ត្រង់នេះហើយព្រៃស្រឡៅលាយចំរុះដោយឈើខ្លាញ់មានបេងនឹងនាងនួនជាដើម ឯដើមឈើឯទៀតៗ គ្មានដុះលាយឡំជាមួយផងទេ ។ រីឯទំហំពុំមានពីរឱបក៏មាន ៣ ឱបក៏មានខ្ពស់ហើយត្រង់ហួសហេតុ ដើមណាក៏ដូចណាដែរដុះជាជួរៗ គួរឲ្យគយគន់ ហើយស្ញើចសរសើរជញ្ជក់មាត់គ្រប់ៗគ្នា ។ អ្នកជញ្ជក់មាត់ជាងគេគឺ ចៅកែឈើម្នាក់ឈ្មោះ ព្រំ-ហែម នៅខាងចំការលើកំពង់ចាម គាត់នាំគ្រួសារទៅមើលបុណ្យឆ្លងព្រះវិហារកាលពីថ្ងៃទី ២ មករា ឆ្នាំ ២៩៦៣ គាត់មានប្រសាសន៍ថា: « គាត់មិនចង់ចេញពីកន្លែងនេះទេ ឃើញឈើនេះកាលណា ហាក់ដូចជារំភើបចិត្តយ៉ាងក្រៃលែង ហើយលែងឃ្លានបាយតែម្ដង» ។ ជិតដល់កំពង់ព្រេង, កំពង់ព្រេងនេះនៅខាងលើកំពង់ប្រណាក , មានភូមិមួយនៅជើងភ្នំត្បែង ហៅថា « ភូមិប៉ាលហាល » ជាភូមិកួយ ។

នេះកំពង់ប្រណាក (គឺខេត្តភ្នំត្បែងមានជ័យនាបច្ចុប្បន្ន មានស្ពាន

ឆ្លងកាត់ប្រហែល ២៥០ម ទឹកថ្លាធ្លង់ ស្ទឹងនេះមកពីកំពង់ត្រាច គឺជាស្ទឹងសែននេះឯង ។

ចេញពីទីរួមខេត្តនេះទៅទល់នឹងជាំក្សាន្ត មានចម្ងាយ ៥៧ គ.ម ហើយមានភូមិនៅតាមផ្លូវ តែដាច់ឆ្ងាយពីគ្នា គឺមានភូមិប៉ូភីន , ពោធិព្រះមេរុ ភូមិនេះមានសាលាបឋមសិក្សាដែរ , អូរផុញ, ភូមិក្រឡាពាសនឹងភូមិឆ្អែះ ភូមិឆ្អែះនេះនៅឆ្ងាយពីផ្លូវថ្នល់ មានផ្ទះច្រើនខ្នង , មានមនុស្សនៅចំរុះគ្នា មានកួយ ,ពាន់ទីនខ្មែរលាវ ៗ ឯមនុស្សច្រើនស្អាត ៗ តទៅនេះ គឺដំបន់ជាំក្សាន្ត ។ គឺជាដំបន់មានសាលាស្រុក, គេហដ្ឋានធំៗបង្គុំតម្រៀបជាជួរ យ៉ាងតេតដាយមានលក់ទំនិញ; មានហាងកាត់ដេរ , មានវត្តអារាមយ៉ាងស្រស់បស់គួរជាទីរមណីយដ្ឋាន ។

ពីជាំក្សាន្តទៅព្រះវិហារ មានចម្ងាយ ៤០ គ.ម. ផ្លូវនេះលោកអ្នកនឹងបានឃើញតែព្រៃព្រឹក្សលតាវល្លិ៍តែប៉ុណ្ណោះ ពុំមានភូមិអ្នកស្រុកទេ ។ លុះទៅដល់ភ្នំព្រះវិហារ ដែលជាកេរ្តិ៍អតីតមហាវីរក្សត្រ ។

ចំពោះរឿងទស្សនាព្រះវិហារ ខ្ញុំមិនបាច់រៀបរាប់ទេ ព្រោះមានសៀវភៅ « កំណត់ចំណាំព្រះវិហារ១ » បានថ្លែងសព្វគ្រប់ហើយ ។

គ)– ពីប្រកបអាជីវកម្ម

របរចិញ្ចឹមជីវិត ដែលប្រជាជននៅដំបន់នេះប្រកប ហើយជារបរដែលខ្ញុំបានឃើញនឹងភ្នែកផងដែរនោះ មានដូចនេះគឺ :-

១- ធ្វើស្រែ

២- ធ្វើចន្ទុះ, ធ្វើដំ

៣- ធ្វើគ្នាត

៤- ធ្វើដើងរេះ

៥- បរបាញ់សត្វ

ពីរបរធ្វើស្រែ

គេតុំធ្វើស្រែ ១ ឆ្នាំម្តងដូចយើងទេ ២ ឬ ៣ ឆ្នាំគេធ្វើម្តង គេដេកស៊ីស្រូវគេអស់ ចានគេធ្វើម្តងទៀត ព្រោះដំបន់គេធ្វើស្រូវកើតយ៉ាងបរិបូណ៌ ឯពូជស្រូវគេច្រើនរើសពូជល្អ ។ ដូចជាស្រូវនាងពេជ , ស្រូវនាងលាជ, ស្រូវនាងពជជាដើម ។ ពូជស្រូវដូចពាប់មកនេះ មានអង្ករទ្រវែងមានរស់ជាតិឆ្ងាញ់ពិសារ ហើយលុយយទៀតផង ។ ស្រូវធ្វើកើតល្អណាស់ម្នាក់ៗ ពាប់រយថាំង ដោយដំបន់នេះជាកន្ទែងទំនាបហើយមានទ្វាញ់ទៀតផង ។ ស្រូវគេមិនលក់ទេ គេទុកចិញ្ចឹមគ្រួសារគេ តែគេដូរចំណីបរិភោគដែរ ។ ខ្ញុំឃើញគេបរិភោគនំបញ្ចាក លុះបរិភោគ ១ ចានហើយ គេមិនយកលុយឲ្យទេ គេបែរជាទៅយកស្រូវមួយតាមៀម(១) មកឲ្យម្ចាស់នំវិញ ។

តែកន្លងរាងប៉ុន្មានឆ្នាំនេះ រដ្ឋាភិបាលសង្គមមានពាយ្យលណែនាំឲ្យធ្វើស្រូវមួយឆ្នាំម្តង ។ ព្រោះមានផ្ទៃគេមនាគមន៍ស្រួលបន្ថិចហើយ ។ អ្នកមក

---

១ តាមៀម = គឺជារង្វាស់ងាល់ស្រូវមួយផ្នែកខាងដំបន់នេះ គេស្ទាញពីពាក ហើយទ្ចុកម្រាស្ងណ៌ឡើស្រ្ចស ។

ទិញស្រូវកើនច្រើន ម្ហ៊ីរហើយកសិករដោយយល់ថាមានប្រយោជន៍ក៏នាំគ្នាទិតខំធ្វើស្រែយ៉ាងអស់ពីហ៊ាន ។

តាមខ្ញុំសង្កេតទៅតំបន់នេះ នឹងមានធញ្ញជាតិយ៉ាងបរិបូណ៌ដូចខេត្ត ចាត់ដំបងដែរទៅអនាគត ។

ឯពលរដ្ឋនៅដំបន់ផ្សារវៀងវិញគេមានការចំរើន នឹងស៊ីវិល័យជាង ពួកដូចបានរៀបរាប់មកខាងលើ ពាងសំលៀកបំពាក់, ពាងចរិយា, ពាងគេហដ្ឋាន ក៏មានរបៀបរៀបរយល្អ គួរជាទីចាប់អារម្ម៉ណ៍ ។

២)- ពីសំលៀកបំពាក់និងការតែងខ្លួននៃពួកកូយ

ស្រី ។ ច្រើនប្រើអាវបំពង់វែងខ្លៀ, សំពត់អន្ទូញ, សំពត់ផ្ទាំងខ្ចៅ, សក់ជួងទៅក្រោយមានកាំប្រមាជាស្នៀតសក់ ។ លំអសក់ស-ខាន់បំផុតគឺប្រេងដូង មានជាក់ផ្ការំដួលជាគ្រឿងក្រអូបលាយជាមួយផង។ នៅត្រចៀកគេពាក់ប្រហោងធំ ។ ហើយពាក់ត្រសាល់ដែលធ្វើពីស្លឹកឈើក្រអូប, ពីភ្ជុកដ៏រ ឬបើគេអ្នកមានគេពាក់ផ្កាច័ន្ទធ្វើពីមាសហ្ការបៀបផ្ការ៉ាច័ន្ទ ជ៉ានាន់ជ្ជ្ជ, មានពាក់កងស្ពាន់ស, ស្ពាន់ក្រហមជ្ជ្ជ ជ៉ាហ្ការ៉ាមាន ។

ប្រុស ។ ច្រើនស្ងៃកបោកត្រឹមផ្ទ្ធ . ជ ជ ក ក្រមាព័ន្ធទៅក្រោយ , ដូចជាពុ ស ជ ចូ ល ចិ ត្ត ក ា រ ប ្ ន ា ន ទ េ ។ តែ ត ាំ ង ប ្ រ ុ ស ត ាំ ង ស្ រ ី ចូ ល ចិ ត្ត ប ំ ផ ុ ត គ ឺ ក ា ន ់ ត ្ ង ។ ព្ រ ោ ះ ដ ំ ប ន ់ ន េ ះ ត ្ ร ូ ជ ា ក ់ ណ ា ស ់ ព េ ល យ ូ ប ។ ឯ ព េ ល ថ ្ ង ៃ ប ៃ ร ជ ា ក ្ ដ ៅ ទ ៅ វ ិ ញ (ន េ ះ ក ็ ដ ូ ច ជ ា ខ េ ត ្ ត ត ន ត ី រ ដ ែ រ ។

តាមបច្ចេកទេស ថាដំបន់ណាក្ដៅដំបន់នោះមានជាតុដែកដូចនេះៗ ដំបន់ហ្នឹង ដែលមានភ្នំដែក ទឹងភ្នំមាស ។ ខ្ញុំនឹងបង្ហាញជូនភ្នំទាំងពីរនេះ ជ.ប់លោកអ្នកនៅទំព័រខាងមុខនេះ ។

ង)- ភ្នំដែក

ភ្នំដែកស្ថិតនៅខាងជើងកូម៉ាំរេចក ខាងលិចរវៀងប្រហែល១៩គ ម នៅក្នុងឃុំជ័យទ្វារ ប្រវែងភ្នំប្រហែល ៤ គ ម មានក្បាលតាវល្ងំធំៗជុំព័ទ្ធជាប់រ៉ាំ ។ តាមអ្នកបច្ចេកទេសចិនប្រជាមានិត បានជីកយកមកស្ទង់មើល ឃើញដែកសុទ្ធសាធ តែនៅខ្ចីពេក ប្រើការពុំទាន់បាននៅឡើយៗ

ច)- ភ្នំលុង

ឯភ្នំលុង «គឺភ្នំមាស» តាំងនៅក្នុងឃុំព្រាល ។ ប្រវែងភ្នំនេះ ប្រហែល ៨គ ម. ។ កាលរយៈប៉ុន្មានឆ្នាំមុនស្រុកតែងតែទៅប្រកបរបរ ជីកលុងយកមាសបានរាប់តែងឡើងសងគ្រប់ៗគ្នា តែមាសនេះនៅខ្វះណាស់ តាមខ្ញុំពិនិត្យ , ឯជាងមាសនៅរវៀងក៏បាននិយាយប្រាប់ខ្ញុំថា: " មាសទឹក ១០ ភ្នំលុងពុំដូចមាសទឹក ១០ នៅទីក្រុងទេ មានទាំងយកមាសទាំងពីរបែបនោះមកផ្ទៀងឲ្យខ្ញុំមើលៗទៅឃើញថាខានពណ៌សខ្វះជាងមាសទីក្រុងមែន គាត់បន្តទៅទៀតថា: ទោះអាំងយ៉ាងណា ក៏ពុំក្រហមដូចដែរ ប៉ុន្តែគេលក់ថ្លៃថោកជាងមាសទីក្រុង ។

តាមដែលខ្ញុំបានសួរផ្ទាល់ចំពោះអ្នកដែលទៅប្រកបរបរជីកមាសច្រើនតែមានឧបសគ្គ ។ តើឧបសគ្គយ៉ាងណា ? គឺថាអ្នកទៅរកជីកមាសច្រើនតែធ្វើដំណើរទៅដោយរទេះគោ ។ ជួនកាល ម្ចាស់រទេះកំពុងតែលុងយកមាសនៅឯភ្នំ គោនៅឯជំរុំឯណោះ ខ្លាចូលកាចកស៊ីទាំងថ្ងៃ ក៏មាន ; ម្យ៉ាងទៀតជីកមាសបានហើយ មានពួកចោរចាំប្លន់យកក៏មានឧបសគ្គនេះ គឺមានតែរៀងរាល់ពេល ព្រោះតំបន់នេះពុំមានរដ្ឋការចុះឡើង ។

ឥឡូវនេះ រដ្ឋាភិបាលបានហាមឃាត់ឈប់ ឲ្យប្រជាជនទៅជីកមាសទៀតហើយ ពីព្រោះគេចង់ទុកមាសនេះឲ្យបានចាស់សិន សមប្រើប្រាស់ រីឯប្រជាជនអ្នកធ្លាប់ប្រកបរបរនេះ ក៏បានផ្អាកឈប់ប្រកបអាជីវកម្មតាមបង្គាប់នៃរដ្ឋាភិបាលរហូតសព្វថ្ងៃនេះ ។

បញ្ចប់

ខេត្តឧត្តរមានជ័យ នឹងមានអារ្យធម៌ដ៏បរិបូណ៌ ក្នុងពេលឆាប់ ៗ នេះ ដោយទាហាននិងស៊ីវិលព្រួតដៃគ្នាយ៉ាងសម្បើម បង្កើតផ្លូវគមនាគមន៍ទៅមក តាមជនបទនានា តែរៀងរាល់ថ្ងៃ ។ ហើយជាពិសេសជាខេត្តមានផលិតផលខាងដ៏រ, ព្រោះឈើធញ្ញជាតិយ៉ាងបរិបូណ៌ទៅអនាគត ។

លេខក្រោយខ្ញុំនឹងជូននូវជីវភាពនៃប្រជាពលរដ្ឋខ្មែរលើ (នាខេត្តរតនគិរី)

លទ្ធផលនៃការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ
នៅធមាសទី ១ ឆ្នាំ ១៩៦៥ ស្តីអំពី "ប្រដាប់
តែងកាយរបស់ខ្មែរ"

នៅធមានទី ១ ឆ្នាំ ១៩៦៥ គឺពីខែមកា . ដល់ដាប់ខែកក្កដា ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបើកការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ១ មុខគឺ "អំពីប្រដាប់តែងកាយរបស់ខ្មែរ" ដើម្បីប្រមូលឯកសារផ្នែកនេះយកមករក្សាទុកជាគោលចារឹកនៃប្រពៃណីរបស់ប្រទេសតទៅអនាគត ។

ក្នុងរយៈកាល ៦ ខែក្រោយដែលបានប្រកាសផ្សាយរួចហើយ ក្រុមជំនុំទំនៀមទម្លាប់ បានទទួលអត្ថបទស្តីអំពីប្រដាប់តែងកាយរបស់ខ្មែរនេះជាបន្តបន្ទាប់គ្នា អំពីសមាជិកធ្វើយធ្វងរបស់ក្រុមជំនុំខ្លះ អំពីបេក្ខជនក្រៅពីសមាជិកខ្លះ ទាំងបញ្ជិតទាំងគ្រហស្ថ ជាប្រើនច្បាប់ ។

ក្រុមជំនុំបានប្រជុំគ្នាពិនិត្យវិញ្ញាសាទាំងនេះយ៉ាងហ្មតចត់ ហើយបានសម្រេចលទ្ធផលដូចតទៅនេះ :

— លោក សុះ-នូវ នៅឃុំកំពង់ហ្លួង ស្រុកពញ្ញាឌ្ឍ ខេត្តកណ្តាល បានជាប់លេខ ១ ត្រូវបានរង្វាន់ ១០០០រ០០

- លោក ចាប-រិត ត្រូបត្រៀននៅសាលាបឋមឡាង ស្រុកកណ្ណាល ស្ទឹង ខេត្តកណ្ណាល បានជាប់លេខ ២ ត្រូវបានរង្វាន់ ៨០០រ០០

លោក រៀ-កុល នៅឃំរង្ឆគាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០រ០០

- លោក សាន-ឌុយ ហៅកែវ-សានឌី នៅសៀមរាបក្រុង បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០រ០០ ។

ក្នុងឆមាសជាមួយគ្នានេះ ក្រៅអំពីការប្រឡង ក្រុមជំនុំបានទទួលឯកសារស្តីអំពីទំនៀមផ្សេង ៗ ជាច្រើនទៀតអំពីសមាជិកឆ្វើយឆ្វងខ្វះ អំពីអស់លោកមិនមែនជាសមាជិកខ្វះ ដែលមានឧត្តមគតិល្អយល់ច្បាស់ នូវប្រយោជន៍ជាតិពិតប្រាកដ បានសរសេរឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ ។

ចំណែករង្វាន់ដែលត្រូវបានជល់បេក្ខជនប្រឡងជាប់ ជល់សមាជិកនឹងក្រៅសមាជិកដែលបានផ្ញើអត្ថបទទៅក្រុមជំនុំនោះ ក្រុមជំនុំបានចាត់ប្រគេន-ជូនរួចអស់ហើយ ។

ក្រុមជំនុំសូមថ្វៃងអំណរគុណយ៉ាងជ្រាលរជ្រៅចំពោះព្រះតេជៈព្រ-គុណ នឹងអស់លោក-អ្នក ដែលបានយកព្រះទ័យយកចិត្តទុកដាក់ជួយរក្សាកេរ្តិ៍ដំណែលរបស់ជាតិដ៏ថ្ងៃថ្នាទាំងអស់នេះជាតិយ្យោភាព ។

មំនៀមអ្នកស្រុកប៉ៃលិន

លោក លី ធាមតេង រៀបរៀង

ភូមិភាគប៉ៃលិនជាដំបន់មួយដែលអ្នកស្រុកយើងចាប់អារម្មណ៍ ដោយហេតុភូមិភាគនេះនៅឆ្ងាយជាប់ស្រុយាលពីកងពាងទីផង ដោយមានបរិយាកាសផ្ទាល់ខ្លួនពីគេផងនឹងដោយមនុស្សដែលរស់នៅទីនោះសុទ្ធសឹងជាជនជាតិកុឡាផង ។ កាលណាបើជាជនជាតិ ខ្មែរដូចនេះ ទំនៀមទម្លាប់នៃអ្នកស្រុកនោះក៏ខ្មែរដែរ តាំងពីរបបរស់នៅរហូតដល់របបកសិដ្ឋានៀ សាសនា ឬ សិល្បៈផ្សេង ។ ។ ហេតុដូចនេះ ក្រុមដំនំទំនៀមទម្លាប់ខ្មែរ ដែលមានការរក្សាទុកឯកសារទំនៀមទម្លាប់គ្រប់ប្រភេទ មាន «ការរស់នៅអ្នកស្រុក» ជាអាទិនោះ ក៏ចាន់ថ ចាំរក្សាទុកនូវឯកសារចាំងច្បាយដែលស្តីពីជីវភាពនៃអ្នកស្រុកខ្មែរយើងគ្រប់មជ្ឈដ្ឋាន ជាពិសេសគឺពួកអ្នករស់នៅតាមស្រុកឆ្ងាយ ។ ឬអ្នកស្រុកដើម ដូចជាខ្មែរលើ ភ្នំ ស្ទឹង ស្ទូចជាដើម ។ មិនតែប៉ុណ្ណោះ យើងបានចាំងចាត់ការពារក ប្រមែប្រមូលបន្ទូមឯកសារថ្មី ។ ទៀត ព្រមទាំងបានចាត់ការឲ្យសមាជិកនៅស៊ើបសួរដល់ក្ងន្ធីចាំងនោះផង ។ ក៏ប៉ុន្តែដោយមធ្យោបាយស្ទូចស្ត្ងើ យើងពុំអាចធ្វើការនេ ឲ្យអស់ហើយភ្លាម ។ ទេ ត្រូវតែធ្វើជញ្ជាប ។ តាមលទ្ធ-ភាពដែលធ្វើទៅបាន ។ កាលណាប្រមូលបាន ល្ងមដ៏ពេញជូនជនរួមជាតិយើងឲ្យបានជ្រាបខ្លះនោះ យើងក៏រៀបចាប់ជាអត្ថបទ ចេះតម្ម្ជ្ជ្ជ្ជ

តែបើមាននៅខ្វះខាតត្រង់ណាទៀត យើងក៏ព្យាយាមស៊ើបសួរស្រាវជ្រាវ យកមកបំពេញឯកសារទុកតទៅទៀត ។ ហេតុនេះ បើលោកអ្នកអានទាំងឡាយ បានជ្រាបការពិតលើសពីសេចក្ដីអធិប្បាយទាំងនេះ ក៏សុំមេត្តាសរសេរផ្ញើទៅក្រុមជំនុំយើងដើម្បីទុកបន្ថែមទៅបោះពុម្ពគ្រាក្រោយទៀត ។

នៅពេលនេះ យើងលើកយកទំនៀមរស់នៅ របស់ពួកកុឡា នៅប៉ៃលិនមកអធិប្បាយដូចតទៅ ៖

១ – ដើមកំណើតស្រុកប៉ៃលិន

ពាក្យថា «ប៉ៃលិន» នេះ ដើមហេតុក្លាយមកពីពាក្យ «កេលេង» តាមសេចក្ដីនិទានថា កាលនោះ មានពួកអ្នកបរបាញ់មួយក្រុមតែងស្ទុះស្ទួងមកធ្វើប្រមាញ់នៅភូមិភាគព្រៃភ្នំ ត្រង់ស្រុកប៉ៃលិនសព្វថ្ងៃនេះ ។ កាលនោះ ពួកប្រមាញ់ទាំងនេះ ប្រទះឃើញមានអូរធំៗ នៅតាមច្រកភ្នំ ដីជ្រាលទំនាប ជាជ្រលងមួយកន្ទ្រង ហើយមាត់អូរនេះ គេតែងប្រទះឃើញសត្វគេ មកប្រឡែងប្រលូកគ្នាតែកន្ទ្រងនេះ ។ កាលណាវាឃើញមនុស្ស វាក៏ផ្អើលរត់ប្រសាចចូលព្រៃបាត់ទៅ ។ ត្រង់មាត់អូរនេះទៀត ដែលពួកប្រមាញ់រើសបានដុំថ្ម ដែលភ្លឺថ្លា នាំយកទៅស្រុកភូមិចែកគ្នាមើលដុំថ្មចំឡែក ១ ផង ។ តមកពួកកុឡាដែលជាអ្នកមានរបរជាងថ្មត្បូង ទិញ-លក់ត្បូងខេត្តចន្ទបុិន (ចន្ទបុរ) ប្រទេសសៀម ក៏ឃើញដុំថ្មល្អៗ ទាំងនេះ សាកសួរពួកអ្នកប្រមាញ់ថាតើបានថ្មនេះមកពីណា? ពួក

នេះក៏ប្រាប់គេថាបានពីកន្លែងត្រៃត្រង់ក្នុងដ «ភ្លេងដ» ។ តមកពួកកុន្ធា
ទោះនាំគ្នាតាមកមកដល់ទីនេះទៅ ហើយក៏នាំគ្នាហៅសំគាល់ក្នុងដនេះ
ថា «ភ្លេងដ។» ដូច្នេះហើតមក ក៏ប៉ុន្តែដោយពួកនោះអានតាមសំឡេងដ
ស្រៀម ក៏នាំឲ្យយើងយ្ងាតបន្ទិចទៀតទៅថា «ផ្លេងន» ដែលសរសេរ
ជាអក្សរឡាតាំងក្លាយទៅជា (Pailin=ប៉ៃលិន) ដូចសព្ទថ្ងៃនេះទៅ ។

២ - ទំនៀមរស់នៅនៃពួកកុន្ធា

ដែលសំគាល់ថាជាទំនៀមរស់នៅវានេះ គឺសំដៅយកការប្រៀបធៀបនៃ
ពួកកុន្ធាចាំងមួលមកនិយាយ តាំងពីចាប់កំណើតកើតជាប្រមកហើតដល់
រៀនសូត្រ រៀបអាពាហ៍ពិពាហ៍ ធ្វើបុណ្យទាន ការកសុីបុណ្យសព។ល។
ប៉ុន្តែពុំអាចបានលម្អិតលម្អន់ក្នុងមួយមុខ ។ ទេ គ្រាន់តែគោល ។ សំរាប់ឲ្យ
យល់ចាន់ហូវហ្គាខ្លះ ។ ប៉ុណ្ណោះ ។ សេចក្ដីអធិប្បាយមានដូចតទៅ ៖

ក- តាំណើត.- តាមទំនៀមអ្នកស្រុកនេះ បើមានកូនកើត
នៅក្នុងគ្រួសារនិមួយ ។ ទំនៀមបង្ក្រាតធ្លាមិនប្ដូកពីអ្នកស្រុកធម្មតាប៉ុន្មាន
ទេ ។ អ្នកដែលទៅសួរផ្ទះ ដើម្បីសាសាទនីងការកើតថ្មីនោះ គេមាន
ទំនៀមមួយ គឺមានការតាតត្រូវរៀបចំផ្ដល់ទឹកសំបូរមួយធ ដប់ក្រមួន
ស្ពុ ១ ក្ដ្រអូបឈ្ងុន ដាក់នៅកណ្ដាលផ្ទះ ត្រង់ក្នុងដែលផ្ដួតការកនោះ
ការណាគ្ងៀមមកដល់ ម្ចាស់ផ្ទះត្រូវលើកផ្ដល់ទឹកនេះជូនគ្ងៀ ហើយគ្ងៀ

ទំនួលបែក រួចគេក៏ប្រោះព្រំទឹកនេះបន្តិចទៅលើភាគប្រសិទ្ធិឲ្យបានសុខ អាយុយឺនយូរ ។ ម្ចាស់ផ្ទះត្រូវអរគុណនឹងភ្ញៀវនេះ ក៏ជូនបារីមួយទៅភ្ញៀវវិញ ។ សុំបញ្ជាក់ថា ទំនៀមពួកកុឡាគេនិយមបារីណាស់ គឺ ទាំងស្រីទាំងប្រុសជក់បារីទាំងអស់គ្នា ប៉ុន្តែបារីនោះមិនមែនដូចបារីយើងធម្មតាទេ គឺមានជាតិថ្នាំជក់តិចតួចណាស់ គេលាយនឹងស្លឹកឈើ ហើយយកសន្ទះស្រទបស្លាស្តើង ៗ មូរពីក្រៅឲ្យមានទំហំប៉ុនមេដៃក៏មាន ប៉ុនមេជើងក៏មាន ប្រវែង ២ឬ៣ សង្ទីម៉ែត្រ ដូច្នេះហើយបានជាការជូនបារីទៅវិញទៅមកនោះ ទុកជាវត្តុសំខាន់មួយដែរ ។

១ – ការរៀនសូត្រ.– ចំពោះការរៀនសូត្រនៃកុមារជនជាតិកុឡា, តាមទំលាប់ពីដើមមក ក្មេងស្រីពុំសូវរៀនទេ, ឯក្មេងប្រុស គេនាំឲ្យទៅនៅវត្ត កាលណាបានអាយុ ៨-៩ឆ្នាំ ឬ ១០ឆ្នាំហើយ ។ ពីដើម ការសិក្សាភាសា-អក្សរ របស់ជនជាតិកុឡា ច្រើនតែរៀនអក្សរនឹងភាសាភូមា (ទំនងដើមហេតុមកពីពួកនេះមានដើមកំណើតពីប្រទេសភូមា ក៏ខំរក្សាចំណេះគេ ប៉ុន្តែសព្វថ្ងៃនេះ រាជការយើងបានបង្កើតសាលារៀនគ្រប់គ្រាន់ហើយពួកអ្នកទាំងនេះក៏រួមជាជាតិខ្មែរពេញលេញទៅហើយនោះ គេនាំគ្នារៀនតែអក្សរខ្មែរវិញដូចសាលាយើងធម្មតាដែរ) ។ ប៉ុន្តែទំនៀមគេនៅជាប់មកត្រង់ដែលកុលបុត្រដែលបានទៅរៀនសូត្រហើយ គេក៏តែបួសជាសាមណេរ ឬជាភិក្ខុៈ ទើបគេទទួលទុកជាពេញលក្ខណៈ ។ វិធីបំបួស

នេះ គេធ្វើយ៉ាងឧឡារិកណាស់ បើទោះបីជាឪពុកម្ដាយពុំសូវសម្បូណ៌ធនធានក៏គង់មានមាក្មេញាតិមិត្តណាម្នាក់ ទទួលឧបត្ថម្ភដែរ ហើយការឧបត្ថម្ភកុលបុត្រឲ្យបួសនេះ ទៅជាជំនឿមួយរបស់អ្នកស្រុកនិយមថានឹងបានកុសលច្រើន ម៉្លោះហើយមានអ្នកចូលចិត្តឧបត្ថម្ភក៏ច្រើនគ្នា ។

តាមទំលាប់ដែលគេធ្វើរួចមកហើយ អ្នកបួសនៅស្រុកនេះ ពុំសូវបានយូរឆ្នាំយូរវស្សាទេ ច្រើនតែមួយវស្សា ឬ ខ្លះទៀតបួសគ្រាន់តែបំពេញកិច្ចប៉ុន្មានថ្ងៃទៅក៏មាន តែបើខានបួសគឺមិនបានឡើយ ។ ដូច្នេះ បើនឹងទទួលកប់គេបុរសពេញលក្ខណៈបាននោះ គឺចំពោះបុរសដែលបានបួសរៀន ។

តាមទំលាប់ពីដើមមក ការសិក្សារបស់អ្នកស្រុកនេះ មិនមានប្រាថ្នាយកចំណេះទៅធ្វើជានាម៉ឺនមន្ត្រីអ្វីឡើយ គឺគេរៀនឲ្យចេះល្មមតែកត់ត្រាកិច្ចការបន្តិចបន្តួចក្នុងគ្រួសារ ឬ សំពប់អានក្បួនតម្រាធម៌អាថ៌តែប៉ុណ្ណោះ ។ ចំណែកនៅពេលសព្វថ្ងៃ ដោយសម្បូណ៌សាលារៀន គេក៏បានចេះដឹងច្រើន ហើយមានធ្វើជាអ្នករាជការខ្លះ ៗ ដែរ ។

ក - អាពាហ៍ពិពាហ៍ .- ចំពោះការរៀបអាពាហ៍ពិពាហ៍កូនចៅនៅស្រុកនេះ ក៏ជាទំនៀមមួយអឹកធឹកណាស់ដែរ ។

តាមទំលាប់មួយប្លែក គឺ គូស្រករថ្មីនិមួយ ៗ នោះ គេច្រើននិយមឲ្យស្គាល់ចិត្តថ្លើមគ្នាជាមុន ដោយគេអនុញ្ញាតឲ្យសាមីខ្លួនបានប្រាស្រ័យ-

គ្នាខ្លះ ៗ ជាមុន ដូចជាជួបគ្នាក្នុងពិធីបុណ្យទាន ឬឡើងចុះផ្ទះរាប់អានគ្នា តាមគន្លងញាតិមិត្តត្រឹមត្រូវ ។ ការស្គាល់គ្នាជាមុននេះ នាំឲ្យសាមីខ្លួនស្ទង់មើលចិត្តថ្លើមគ្នាខ្លះ ៗ ។ កាលបើសាមីខ្លួនព្រមព្រៀងហើយ ចាស់ទុំក៏ស្ដីដណ្ដឹងតាមទំនៀមជាក្រោយ ។ ការស្ដីដណ្ដឹងនេះ គេច្រើនធ្វើតាមរយៈ « ជន្លោ » ដែលជាមនុស្សចាស់ព្រឹទ្ធាចារ្យម្នាក់មានចរិយាត្រឹមត្រូវ អ្នកភូមិទទួលគោរពប្រណិប័តន៍គ្រប់ ៗ គ្នា ។ ហេតុនេះហើយបានជាពួកអ្នកស្រុកនេះ គេរក្សាវិន័យតាមទំនៀមទម្លាប់គេល្អហ្មត់ចត់ណាស់ ព្រោះតែគេគោរពជន្លោប្រចាំភូមិនេះ ។

លុះបានពេលកំណត់រៀបការហើយ ឪពុកម្ដាយត្រូវដើរជំរាបភ្ញៀវ ដោយយកបារីទៅជូនមួយ ៗ គ្រប់គ្នា ជាការគួរសមផង ។ ដល់ថ្ងៃការរៀបលៀងទំនែកទឹកតែ ឥតបាយសំឡទេ ។ ជន្លោអញ្ជើញមកធ្វើជាអធិបតីពិធីនេះ អង្គុយពែនភ្នែននៅក្បាលកន្ទេលដែលកូនប្រុសស្រីសំពះអង្គុយផ្ទឹមគ្នា ។ ឯសំលៀកបំពាក់សាមីខ្លួនទាំងពីរនាក់ក្នុងពិធីនេះ គេនិយមតាមបែបស្រុកគេដែរ គឺប្រុសស្លៀកសារុងសៀតថ្នក់ពីមុខពាក់អាវសដៃធំវែងត្រឹមចង្កេះ ឯស្ត្រីវិញក៏ពាក់អាវរបៀបគ្នានេះដែរតែស្លៀកសំពត់សំឡុយមានជរជាយ ទីងមានផ្កាធំ ៗ លើក្បាលគេមួរសក់ឡើងជាមួយពំនូកហើយយកផ្កាស្រស់ក្រងជាភួងពាក់ព័ទ្ធពំនូកសក់នោះ ឬក៏យក

ខ្សែលោហធាតុមានរស្មីភ្លឺ ៗ ចងព័ទ្ធជុំវិញក៏បាន ។ នៅចំហៀងខាងស្តាំ មានផ្កាមួយបាច់ក្រងជាប់យោលភ្ជាប់នឹងចំណងនេះផង ។ លុះក្រោយមក ដែលគេនិយមអុតសក់ គេក៏គ្រាន់តែយកកម្រងផ្កាមួយមកចងចំហៀងសក់ក្បាលខាងស្តាំធ្វើលំនាំដូចក្បាំង(១)ណាក៏បាន ។

នៅពេលព្រឹកមុននឹងសំពះផ្ទឹមឲ្យដង្ហើប្រសិទ្ធពរ នេះមានពិធីដង្ហែកូនកំលោះទៅកាន់ផ្ទះខាងស្រីយ៉ាងអឹកធឹក គឺអ្នកដង្ហែកូនកំលោះដើរកាន់ផ្កាមួយបាច់ម្នាក់ៗ ច្រើនគ្នា ស្លៀកពាក់ស្អាតតាមទំលាប់គេ គឺ ស្លៀកសារុងអាវបំពង់ខ្លួនខ្លីដៃធំមានឆ្នួតក្បាលឬពាក់មួក ។ លុះក្បួនហែទៅដល់ទ្វាររបងផ្ទះខាងស្រីហើយត្រូវពួកខាងស្រីគេនាំគ្នាឃាំងផ្លូវចូល លុះត្រាតែពួកខាងប្រុសឲ្យអ្នកផ្លូវទៅនិយាយសុំផ្លូវសិន ។ ការសុំផ្លូវនេះ គេច្រើនតែនិយាយពាក្យពង្វាងជាប្រការផ្សេង ៗ ដូចជា សួរថាផ្ទះនេះមានត្បូងលក់ទេ ? បើគេឆ្លើយថាមានក៏សុំមើល , គេទារឈ្នួលឆ្នើនប៉ុន្មាន ៗ ទើបឲ្យមើល ។ ពួកខាងប្រុសក៏ថាព្រម ហើយក៏ហុចលុយកាក់ឬវត្ថុអ្វីមួយជានិមិត្តរូប រួចក៏នាំកូនកំលោះចូលទៅ ។

(នៅមានត)

១– របាំងពាក់នៅលើក្បាល ។

វិវត្តន៍នៃអក្សរខ្មែរ

(ត)

លោក ឌ. ឥម រៀបរៀង

សិលាចារឹកប្រាសាទព្រះខ័ន

ខ្ញុំសូមជូនបែបអក្សរនៅប្រាសាទព្រះខ័នទុកគ្រាន់ឲ្យលោកអ្នកហាត់-អាន ។ អក្សរនៅប្រាសាទព្រះខ័នគឺ នៅសម័យព្រះបាទជ័យវរ្ម័នទី ២ គ្រិស្តសតវត្សទី ៩ ។

ព្យញ្ជនៈ:



ស្រៈ:



ព្យញ្ជនៈ ឋ មិនទាន់ឃើញមានប្រើនៅដើមពាក្យទេ ឃើញប្រើតែនៅជាព្យញ្ជនៈតម្រួត។ ដើម ឬ.ច្ឆ ចាំងពីនេះមានរាងដូចគ្នា ឧទាហរណ៍

អាយ៉ស្លាន = អាយហ្លួន   កាឡ្ហយ៉ា = កាព្លោយ៉ា

ព្យញ្ជនៈ ឌ ឃើញ ក្ដី ដូចជា ឌ បច្ចុប្បន្នខ្លះ ឃើញដូចជា ទ មួយកំណាត់ ដើង ឌ មួយកំណាត់ៈ

បញ្ញិតា = បណ្ឌិត   គុន្ធ = គ្រុន

ជើងអក្សរ ប្រ សម័យនោះ ប្រើឃ្លៀងឃ្លាតពីកន្លែងសម័យបច្ចុប្បន្នបន្តិច ហើយមានពង្រត់ទៅទ្ធងមិនដូចសម័យសព្វថ្ងៃទេ ដូចឧទាហរណ៍ខាងក្រោម

ព្យញ្ជនៈសម័យសតវត្សទី៩ នៅប្រាសាទព្រះខ័ន បើពិនិត្យមើលទៅ ហាក់ដូចជាក្បាច់ ខ្ញុំសូមជូនព្យញ្ជនៈខ្លះមកឲ្យលោកពិនិត្យ ហើយខ្ញុំសរសេរជាបែបអក្សរខ្មែរសម័យបច្ចុប្បន្នផង ។



កាម្ពោយានូក្សំណាស្សាមិ	ឆ្និយគោវម្ចេស្ងរាទយស៊ិ
គេន ប្រតិម្ជិតា ទេវ	វិមត៌ិ ទ្វាទគោត្តរា ។
ឆ្នើចាម្យេម្ងរវិវទ្យាស៊ិ	ត្រឹឥត្យឆ្ងិមតស្សុរាស៊ិ
គោវិយាម្សិវបាទាទ្យាស៊ិ	ចត្វារឹឥត្ស្រតិស្ជិតាស៊ិ ។
ឯគោ ត្រីហិត្ថូហ	ទេវម្ចង្ត្រមេម្ចុ បុន ទឥ
ចត្វារគ្ជោបកាយាិយាមិ	អាវោត្យាយតនេ ត្រយស៊ិ
ទ្វារេម្ចុ ច ចតុទ៌ិក្សុ	ចតុវិមតិទេវតាស៊ិ
ឯតេឥតានិចត្វារិ	ទេវាស្ត្រឹ . . . .

សម៉យអង្គរ

បែបអក្សរខ្មែរសម៉យអង្គរ យើងឆ្លរាប់តាំងពី ត.ស-៨០២ ។ តែត្រិស្តសករាជ ៨០២ ឲ្យំចាត់ទុជាថាមហានគរទៅវិញ ។ សម៉យអង្គរឲ្យំរាប់ត្រឹមពីសតវត្សទី ១៥ (ត.ស-១៤៤២ ដល់ ត ស-១៨០០) ។ សម៉យអង្គរនេះ ឲ្យំរាប់ថាជាសម៉យមួយដែរ ព្រោះអក្សរខ្មែរយើងសម៉យនោះមានលំនាំបុងក្រោយគេបង្អស់ដែលចារឹកនៅលើសិលា ។

នៅសម៉យសិលាចារឹកអង្គរ យើងឆ្លរយកសិលាចារឹកជយ៉ន្ទូដែលជាសិលាចារឹកក្នេងាងគេ ហើយជំនាន់មានស្ងឹកវឹត ។ សិលាចារឹកជយ៉ន្ទូជាតាសាខ្មែរ ក្នុងសម៉យដែលប្រទេសយើងប្រើមហាសករាជ ។ នៅលើ

ជ្ជាំផសិលាចារឹកនោះ គេឃើញមានកាលបរិច្ឆេទពេញគ្រប់គ្រាន់ ។ សិលាចារឹកនោះ គេចារនៅក្នុងគ្រិស្តសតវត្សទី ១៨ ។ សិលាចារឹកនៅសម័យនេះ មិនសូវពិបាកអានប៉ុន្មានទេ ពាក្យពេចន៍ក៏កាន់តែមានលំនាំទិតចូលមកកអក្សរសាស្ត្រខ្មែរសម័យបច្ចុប្បន្ន ។ តែគេសរសេរប្ដូចារមិនគិតយកស្ទួនអក្ខរាវិរុទ្ធិជាគោលទេ គេសរសេរឲ្យតែអានបានចំណាំបាន ។ មុននឹងខ្ញុំជូនប្រយោគខ្ទះ ខ្ញុំសូមជូនព្យញ្ជានៈ

ក ខ្ខ ក្ក ឃ ឆ ឌ ឌ្ឍ ណ ញ

ណ ត្ត ថ ទ្ធ ឆ្ឌ ន្ន

ប្ឋ ជ ញ្ជ ត្ត ម្ម យ ម្រ ស្ស ឡ ក ស្ស ហ

១-របៀបសរសេរតាមសិលាចារឹកជំយ៉ងឆ្ឌ

ស្រៈដែលមានប្រើនៅសិលាចារឹកនេះ ឃើញមានប្លែក ។ ពីគ្នាជួនកាលគេសរសេរជូច្នេះ ជួនកាលសរសេរជូច្នោះ

១. តោ ជួនកាលសរសេរតោយ

១ - ស្រៈ អ ច្រើនតែសរសេរជាមួយស្រៈ ៤-1.

១ មោក = មក , ជោង = ជង

២- ស្រៈ អិ សរសេរដូច្នេះ ។. សើលសាស=សិល្បសាស្ត្រ

តើប=តិប ។

៣- ស្រៈ អី សរសេរដូច្នេះខ្លះ ិ្យ ដូច ី ខ្លះ

១- ស្រតិ=ស្រដី, ពិត្យតើម្ព=ពីដើម ។

៤. ស្រៈ អឹ សរសេរជាស្រៈ ិ ខ្លះ ជាជើង ្យ ខ្លះ

១- សិងបូល=សឹងបូល, ត្យង=ដឹង

៥ ស្រៈ អឺ សរសេរជា ឹ ខ្លះ ជា ិ ខ្លះ ។ ហ៊ិណា=ម៉ឺន

គិបិ=គឺបឺ ។

៦- ស្រៈ អួ គេសរសេរដោយយកជើងព្យញ្ជនៈ វ្វ ដំនួស

ឬសរសេរទីនស្រៈ អុ ។ រ្វក រ្វប ម្យ មួយ ។

៧- ស្រៈ អើ ជួនកាលគេសរសេរ ែ ខ្លះ ជួនកាលសរសេរ

ដូចសព្វថ្ងៃខ្លះ ។ លេិក=លើក, ប្រេិន=ប្រើន

៨- ស្រះ អឿ ឃើញមានសរសេរដូចសព្វថ្ងៃនេះខ្លះដែរ តែ

កន្លែងខ្លះមិនសរសេរដូចសព្វថ្ងៃទេ

១- ក្បៀង=ក្បឿង ។

៤. ស្រះ អ្អែ សរសេរជា ៖ បិញ =បេញ បិក = បក

២. សញ្ញា និងវណ្ណយុត្តិខ្លះនៅសិលាចារឹកជ័យ ឥន្ទ

១. មូសិកទន្តនៅក្រោមព្យញ្ជនៈ មានន័យថាព្យញ្ជនៈនោះមានស្រះ អ ៖ ជាបុង្គ្រ=ជារបង តែជួនកាលគេថាស្រះ អា ៖ ពុទ្ទក=ពំនាក់

២- សំយោគសញ្ញា មានន័យពីរយ៉ាង

ក)- ជំនួសព្យញ្ជនៈ ង ៖ សង៉=សង្ឃ

ខ) ជំនួសបន្តក់ ៖ តាក៉=ដាក់

ពាក្យខ្លះនៅសិលាចារឹកជ័យ ឥន្ទ

ច្រើនត្រៃពក្រោយ ប្រយោជន៍វិទ្ធផល...

កាន់ត្រៀមត្រប្បត្ត សម្រាប់ភ្ញៀវ...

រួចត្រប់ពិស្ការ មានផ្កាខ្យយ...

មានបន្ទាយ្យ អន្តប្បសាលា

ផ្នែកកំណត់និងប្រវត្តិការណ៍

ព្រះរាជដំណើរ

សម្តេចព្រះសុឧម្មាឧបតី ព្រះសង្ឆរាជថ្នាក់ទី ២ គណៈធម្មយុត្តិកនិកាយ ស្តេចយាងទៅកាន់វត្តកែវបុិទ្ធារាម ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្ត-កំពង់ឆ្នាំង ។

កាលពីថ្ងៃអាទិត្យទី ៤ ខែកក្កដា ឆ្នាំ ១៩៦៥ វេលាម៉ោង ៧ ព្រឹក សម្តេចព្រះសង្ឆរាជថ្នាកទី ២ នៃគណៈធម្មយុត្ត ទ្រង់ស្តេចយាងទៅបំបួស កុលបុត្រនៅវត្តកែវបុិទ្ធារាម ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដោយសេចក្តីសុំស្តេចយាងពីលោកវរសេនីយ៍ឯក ខ្ជូត-ប៊ុត មេបញ្ជាការ ឋបនីយសាកលនៅរមាស ព្រមទាំងពួកពុទ្ធបរិស័ទនៅទីនោះ ។

សម្តេចស្តេចយាងដោយព្រះទីនាំងរថយន្តផ្ទាល់ព្រះអង្គ មានព្រះ សង្ឆរាជាគណៈឋានានុក្រម មន្ត្រីអ្នករាជការនិងឧបាសក-ឧបាសិកាជា ច្រើន មានលោក ច័ន្ទ-សុន នាយកមន្ទីរក្រសួងធម្មការជាដើម បានតាម ហែជូនព្រះរាជដំណើរផង ។

ព្រះរាជដំណើរស្តេចយាងដល់ទីរួមខេត្តកំពង់ឆ្នាំង មានអ្នករាជការ ខេត្តគឺលោក ផ៉ែត-រ៉ុង តួយួយខេត្តទី ១ និងលោក ឯក-សារិន ព្រះរាជ អាជ្ញាសាលាដំបូងខេត្តកំពង់ឆ្នាំង ព្រមទាំងកងរាជតម្ត្រួតចាំទទួលធ្វើតារវ-

កិច្ចនិងជួនព្រះពរដំណើរសម្តេចបន្តទៅទៀត ដោយមានវេយ្យាវច្ចកងពាជ តម្រូតរៀបចំការយោងមុខរហូតដល់ត្រូវកែវប៊ីង្ហាម ។

ព្រះពរដំណើរស្តេចយាងដល់ទីប្រជុំជនសាលាស្រុកទឹកជ្ញុស លោកចៅហ្វាយក្រសួងគង្គារុទ្ធ និងប្រមាញ់ព្រមទាំងសហការ លោកគ្រូនិងសិស្សានុសិស្សជាច្រើនរយនាក់ ចូលឈរតម្រៀបគ្នាជាជួរអបសងខាងផ្លូវចាំធ្វើការកិច្ចថ្វាយសម្តេចព្រះសង្ឆរាជ ។ បន្ទាប់ពីអ្នកពាជការសាលាស្រុកនិងសិស្សានុសិស្សនោះទៅ មានក្រុមតាហានឈរអមព្រះពរដំណើរលើកដៃឡើងនមស្ការគោរពគ្រប់ៗគ្នា ។ បន្ទាប់ពីនោះទៅទៀតមានក្រុមពួកតុន្ទបរិស័ទប្រុស-ស្រីឈរចាំគោរពសម្តេចរហូតដល់ចូលទៅក្នុងវត្ត ។

លុះព្រះទីនាំងចូលដល់ក្នុងវត្ត ទើបមានព្រះសង្ឆរាជាគណៈហ៊ានានុក្រម និងកិត្តិយោធិចារ្យ ណុប-គី ចៅអធិការវត្តនោះ ព្រមទាំងកិត្តិសាមណេរចាំទទួលព្រះពរដំណើរ សម្តេចរហូតដល់ទៀនសាលាបុណ្យ ទៅអមដណ្តើរចូលទៅកាន់សាលាបុណ្យនោះ មានលោកវរសេនីយ៍ឯក ខ្ចូត-ប៊ុត ព្រមទាំងលោកស្រី លោកវរសេនីយ៍ពេ ថោង-ហ៊ី លោកវរសេនីយ៍ពេ គឹម-ពោសល និងអស់លោកជានាយតាហានឯទៀតជាច្រើនចាំគោរពនមស្ការទៅត្រង់ទីនោះ ។

សម្តេចទ្រង់យាងចុះពីព្រះទីនាំងរថយន្ត ទទួលការក្រាបបង្គំពីព្រះសង្ឆ និងវរជនព្រមទាំងពួកតុន្ទបរិស័ទរួចហើយ ទើបស្តេចយាងឡើងគង់

ប្រថាប់លើសាលាបុណ្យ ដែលមានរំលេចរចនាលំអដោយក្បូរជាតិផ្សេងៗ និងវង់សាសនា ។ សម្ដេចព្រះសង្ឃរាជទ្រង់សម្រួលព្រះឥរិយាបថបន្តិចមក ហើយលោកវរសេនីយឯក ឡុត - ប៊ុត តំណាងព្រះសង្ឃនិងពុទ្ធបរិស័ទគ្រប់ប្រភេទ បានថ្លែងសុន្ទរកថាថ្វាយពរស្វាគមន៍និងសំដែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ សម្ដេចព្រះសង្ឃរាជដែលទ្រង់សព្វព្រះរាជហឫទ័យស្ដេចយាងមកទាំងមានការនឿយព្រួយព្រះកាយពលទាំងអម្បាលនេះ អាចបញ្ជាក់ឲ្យឃើញច្បាស់នូវព្រះរាជហឫទ័យដែលទ្រង់ប្រកបដោយព្រះមហាករុណាដ៏លើសលប់ ចំពោះពុទ្ធបរិស័ទដែលស្ថិតនៅក្នុងទីឆ្ងាយដាច់ស្រយាលនេះផង ដើម្បីចង់ទតមើលនូវការស្ថាបនាវត្តថ្មីនេះផង និងដើម្បីប្រោសព្រះរាជទាននូវឱវាទដល់ពុទ្ធបរិស័ទក្នុងទីនេះផង មិនតែប៉ុណ្ណោះ ទ្រង់បានឲ្យនាំយកមកនូវកន្ទេលខ្សែយ៉ាងវែង ១ ចំនួន ៣ ខ្សែ និងប្រេងកាត ១ ប៉ោតមកប្រទានដល់វត្តថ្មីនេះទុកឲ្យប្រើប្រាស់ផងទៀត ។ ព្រះកាយវិការនេះហើយដែលជាហេតុនាំឲ្យពុទ្ធបរិស័ទនៅទីនោះជ្រះថ្លាត្រេកអរយ៉ាងក្រៃលែង ដែលពុំអាចនឹងបំភ្លេចបានដរាបដល់ជីវិតាវសាន ។

ជាទីបញ្ចប់លោក លោកវរសេនីយ៍ឯក ឡុត-ប៊ុត បានថ្លែងសុន្ទរកថាប្រសិទ្ធិពរថ្វាយសម្ដេចព្រះសង្ឃរាជជួនណាតនេះ ។

សុន្ទរកថាស្វាគមន៍

សូមព្រះតេជះតម្កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទសម្តេចព្រះ

សុធម្មាធិបតី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ

សូមទ្រង់ជ្រាប

ទូលព្រះបង្គំជាខ្ញុំ ក្រោមល្អងធូលីព្រះបាទតាំងនាមលោកគ្រូចៅអធិការ - ភិក្ខុ សាមណេរអាចារ្យសម្រាប់វត្ត ឧបាសក-ឧបាសិកា គណៈកម្មការវត្ត កែវប៉ុត្តាពមទាំងអស់ និងកូននាមផ្កាល់នៃទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត សម្តេចជាអម្ចាស់ ដើម្បីថ្លែងថ្វាយនូវព្រះពរស្វាគមន៍ដូចតទៅនេះ

សូមទ្រង់ព្រះមេត្តាប្រោស

នាទិវាដ៏ប្រកបដោយនក្ខត្តឫក្ស ជាមង្គលសួស្តីមហាប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំគ្រប់រូបមានបីតិសោមនស្សរីករាយជាអតិបរមា រកតែអ្វីមកប្រៀបប្រដូចពុំបាន ក្នុងការដែលសម្តេចជាអម្ចាស់ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទៀតយកនូវព្រះបរមរាជឱកាស ស្តេចយាងមកជាព្រះរាជាធិបតី ដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបំបួសនាគនេះ ដែលជាហេតុនាំឲ្យបរិយាកាសមានសភាពរុងរឿងជាអនេកប្បការ ។

សូមទ្រង់ព្រះមេត្តាប្រោស

ព្រះរាជដំណើរស្ដេចយាងមកកាន់ទីនេះរបស់ព្រះអង្គសម្ដេច បាននាំឲ្យទូលព្រះបង្គំទាំងឡាយ មានសេចក្ដីរីករាយជាកិយោភាពដោយមានក័ពវស្នាដ៏ខ្ពង់ខ្ពស់ បានធ្វើការរំភក្ដីស្មោះអស់ពីដួងចិត្តរបស់ខ្លួន ថ្វាយចំពោះសម្ដេចជាអម្ចាស់ផ្ទាល់ព្រះភ័ក្ត្រ ទីងបានស្ដាប់ផ្ទាល់ពីព្រះឱស្ឋ ទូលព្រះបរមរាជោវាទក្នុងពេលនេះផង ។

បុត្រសម្ដេចជាអម្ចាស់

សូមសម្ដេចជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោសព្រះរាជានុញ្ញាតទូលសេចក្ដីផ្ដាំផ្ញើដែលកើតឡើងដោយអចេតនា របស់ទូលព្រះបង្គំជាខ្ញុំក្រោមលម្អងធូលីព្រះបាទទាំងឡាយ ក្នុងការរៀបចំធ្វើបដិសណ្ឋារកិច្ចថ្វាយចំពោះលម្អងធូលីព្រះបាទ ក្រែងមានការដែលពុំសមរម្យត្រង់កន្លែងណាខ្លះនោះ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជានុគ្រោះ ចំពោះទូលព្រះបង្គំជាខ្ញុំទាំង-ឡាយ ព្រោះទីអាពមនេះទើបនឹងចាប់បដិសន្ធិឡើងពីថ្ងៃទី ១៨ ធ្នូ ឆ្នាំ ១៩៥៤ គឺទើបនឹងមានអាយុបាន ៧ ខែប៉ុណ្ណោះ ពុំទាន់មានសម្ភារៈសព្វគ្រប់ ដើម្បីនឹងរៀបបដិសណ្ឋារកិច្ចឲ្យបានជាមហោឡារិកទៅបាន ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំទាំងឡាយបរក្រោមលម្អងធូលីព្រះបាទ សូមថ្វាយទូលព្រះសព្វាគមន៍ចំពោះសម្ដេចជាអម្ចាស់ សូមឲ្យការគង់ប្រថាប់នៅរបស់ព្រះ

អង្គគង់គង់នៅលើទីនេះនឹងព្រះរាជដំណើរយាងនិវត្តន៍ បានប្រកបដោយសុវត្ថិភាព កុំបីឃៀងឃ្លាតឡើយ ។

ម្យ៉ាងទៀតទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលើកយកនូវមហាបុញ្ញកុសល ដែលបានធ្វើក្នុងពេលនេះទាំងអម្បាលម៉ាន ថ្វាយចំពោះសម្ដេចជាអម្ចាស់ សូមអានុភាពនៃកុសលកុសលទាំងនោះជួយពិតក្តីរក្សាព្រះអង្គសម្ដេច សូមបានប្រកបដោយព្រះបរមសុខភាពក្សេមក្សាន្តគ្រប់ទិវាពេលរាត្រីកាល ហើយសូមគុណបុណ្យនៃព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយអភិបាលទ្រទ្រង់ព្រះអង្គសម្ដេចជាអម្ចាស់ សូមទ្រង់ប្រកបតែនឹងពុទ្ធពរទាំង៤ប្រការ កុំបីមានព្រះរោគាពាធអ្វីមួយមកបៀតបៀនព្រះកាយព្រះអង្គបានឡើយ សូមមានព្រះជន្មវស្សាទីឃាយឺនយូរជាង់រយព្រះវស្សា ដើម្បីនឹងបានជាម្លប់សម្រាប់ជ្រកកោន នៃពុទ្ធបរិស័ទគ្រប់ប្រភេទអស់កាលជាអង្វែងតរៀងទៅ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះតេជះគុណលើត្បូង

លុះចប់សុន្ទរកថាថ្វាយពរស្វាគមន៍ នៃលោកវរសេនីយ៍ឯក ខ្វុត-ប៊ុត នោះហើយ សម្ដេចព្រះឧបរាជទ្រង់សព្វព្រះរាជហឫទ័យថ្លែងព្រះសន្ថវកថាតបវិញ ដោយមានសេចក្ដីជាអាទិ៍ថា សម្ដេចទ្រង់មានព្រះអំណរណាស់ ដោយបានឃើញពុទ្ធបរិស័ទគ្រប់ប្រភេទ បានរួបរួមសាមគ្គីចងបាច់គ្នា មក

រដ៏ចាំទទួលធ្វើតាវកិច្ចចំពោះព្រះអង្គ ។ សម្តេចទ្រង់មានព្រះបន្ទូលគោតសរសើរជាពិសេស ចំពោះវិចារណញ្ញាណប្រកបដោយទុក្ខមត្តិដ៏ខ្ពង់ខ្ពស់នៃលោកវរសេនីយ៍ឯក ខ្ងូត-ប៊ុត ដែលបានផ្ចង់ផ្តើមដឹកនាំកូនចៅរបស់លោកនិងពុទ្ធបរិស័ទ ហើយបានលះបង់ទូវដ៏ជាកម្មសិទ្ធិរបស់ខ្លួនសាងធ្វើជាវត្តថ្មីនេះ ដើម្បីប្រតិស្ឋានព្រះពុទ្ធសាសនាផង និងប្រយោជន៍ដើម្បីឲ្យពុទ្ធបរិស័ទដែលនៅឆ្ងាយជាច់ស្រយាលនេះ ងាយស្រួលក្នុងការទៅមកបំពេញបុណ្យកុសលផង ។

ម្យ៉ាងទៀតទ្រង់មានព្រះបន្ទូលសរសើរដល់ស្នាដៃលោកវរសេនីយ៍ឯក ខ្ងូត-ប៊ុត ព្រមទាំងសហការីរបស់លោក និងពុទ្ធបរិស័ទក្នុងទីនេះទាំងអស់ថា ទ្រង់ពុំដែលបានឃើញការស្ថាបនាវត្តណា ដែលមានរយៈពេលតែជាង ៥ ខែប៉ុណ្ណោះ ហើយមានការលូតលាស់ជុះសមិទ្ធិច្រើនប្រាដ៏ច្រើនហួសពីសេចក្តីស្មាន ដូចជាវត្តនេះសោះទេ ដូច្នេះសូមឲ្យអស់លោកខំបន្តសេចក្តីព្យាយាមប្រឹងប្រែងនោះតទៅទៀត ដរាបណាបានសម្រេចដល់ទីដៅរបស់អស់លោកគ្រប់ ១ គ្នា ។

ជាទីបំផុតសម្តេចព្រះសង្ឆរាជ ទ្រង់ប្រោសព្រះពរជាគន្ធពរ សូមឲ្យការកសាងរបស់អស់លោកអ្នកនេះ បានដឿនលឿនតម្រង់ទៅ ពុំបីមានឧបសគ្គអ្វីមកជាប់ពាក់ព័ន្ធបានឡើយ ទាំងសូមឲ្យលោកអ្នកទាំងឡាយបានជួបប្រទះតែនូវសេចក្តីសុខចំរើន តាំងពីពេលនេះតទៅរហូតដល់ព្រះ

និទាន ៗ ជាពិសេសសម្តេចព្រះសង្ឃរាជទ្រង់មានព្រះបន្ទូលផ្តាំថា ដរាបណាអស់លោកអ្នកពុំទាន់បានលុះដល់ព្រះនិព្វានទេ សូមឲ្យអស់លោកអ្នកមានសាមគ្គីប្រមូលគ្នាហើយក៏បំពេញមនុស្សធម៌គឺសីល ៥ និងកម្មបថ ១០ ឲ្យបានគ្រប់ ៗ គ្នា កុំគប្បីធ្វេសប្រហែសឲ្យសោះ ព្រោះថា យើងដែលបានកើតមកជាមនុស្សនេះ មិនថាធំតូចមានទ្រព្យឬក្រទ្រព្យទេ ចាត់ថាជាអ្នកមានមហាភ័ព្វប្រសើរណាស់ ហើយបានជួបនឹងព្រះពុទ្ធសាសនាទៀតផង ដូច្នេះគួរកុំបណ្តែតបណ្តោយឲ្យខូចជាតិកំណើតជាមនុស្សនេះសោះឡើយ ៗ

នៅល្ងាចថ្ងៃ-ខែ-ឆ្នាំដដែលនោះ វេលាម៉ោង ១៧ សម្តេចព្រះសង្ឃរាជនិងព្រះសង្ឃទាំងពួងទ្រង់ប្រទានពុទ្ធមន្តចំរើនព្រះបរិត្ត ហើយបំបួសកុលបុត្រ ទ្រង់ប្រោសប្រទានព្រះធម្មទេសនា រហូតដល់ម៉ោង ២១ ទើបចប់សព្វគ្រប់ ៗ

យើងសូមបញ្ជាក់ថា បច្ច័យដែលពុទ្ធបរិស័ទបានបូជាធម្មទេសនានៅពេលនោះចំនួន ២.០០០៛០០ សម្តេចទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានបច្ច័យជូនទៅលោកវរសេនីយ៍ឯក ខុត - ប៊ុត ជាប្រធានគណៈកម្មការស្ថាបនាវត្តថ្មីនោះ ដើម្បីជួយជាកំលាំងក្នុងការកសាងវត្តនោះតទៅទៀត ៗ

ក្រុមពុទ្ធបរិស័ទទាំងឡាយចំណុះវត្តកែវប៊ីឡាវាម ដែលមានលោកវរសេនីយ៍ឯក ខ្ពូត-ប៊ីត ជាប្រធាន បានលើកយកមហាកុសលដែលកើតអំពីការកសាងវត្តថ្មីនេះ ព្រមទាំងបំបួសកុលបុត្ត និងធម្មទានអាមិស្សទានទាំងអម្បាលនេះ ថ្វាយជាព្រះរាជកុសលចំពោះសម្តេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋសូមទ្រង់ប្រកបដោយព្រះបរមសុខក្សេមក្សាន្តឈ្នះអស់សត្រូវគ្រប់ទិសទី មានព្រះជន្មវស្សាយឹនយូរជាងរយព្រះវស្សា ដើម្បីបានជាជម្រកនៃព្រះពុទ្ធសាសនា និងប្រជាពលរដ្ឋជាកូនចៅព្រះអង្គអស់កាលជាអង្រឹងតទៅ ។

ពេលព្រឹកថ្ងៃចន្ទ ទី ៥ ខែកក្កដា ឆ្នាំ ១៩៦៥ វេលាម៉ោង ៧-១៥ នាទី សម្តេចព្រះសង្ឃរាជទ្រង់ស្តេចព្រះរាជនិវត្តន៍មកកាន់ក្រុងភ្នំពេញវិញ ដោយមានក្ឃួនជូនព្រះរាជដំណើរ ជូចកាលដែលស្តេចយាងទៅដែរ ។

ព្រះទីនាំងរថយន្តបានដឹកនាំព្រះរាជដំណើរ សម្តេចព្រះសង្ឃរាជដល់វត្តបទុមវតី នៅវេលាម៉ោង ១០ ព្រឹក ដោយព្រះសុវត្ថិភាព ។

ដំណឹងពីក្រសួងធម្មការ

តាមដីកាលេខ-១៣០-សស ចុះថ្ងៃទី ៣០ មិថុនា ១៨៦៥ នៃ
ក្រសួងធម្មការគ្រូបង្រៀនជាប់កិច្ចសន្យានៃភ្នំពិតបឋមសិក្សា ដែលទើប
ទទួលជាប់សមយ៉ាងថ្ងៃទី ២៤ មិថុនា ១៨៦៥ ហើយដែលមានពាយនាម
ដូចតទៅនេះ ត្រូវចាត់ឲ្យទៅបំពេញមុខងារជាចាងហ្វាងសាលារៀនទីផ
ជាគ្រូប្រចាំថ្នាក់ ចាប់តាំងពីថ្ងៃ ១ កក្កដា ១៨៦៥ តទៅនៅសាលា
ពុទ្ធិកបឋមសិក្សាក្នុងវត្តតាំងឡាយដូចខាងក្រោមនេះ

ព្រះមហា ទុម - ជន វត្តកែវកុងខេត្តចាត់ដំបង -ស្រុកសង្កែ
លោក យឹម -សំអូន វត្តស្វាយអាត់ក្នុងខេត្តត្រៃវែង -ស្រុកកំចាយមារ
ព្រះមហា អាំ - ធន វត្តសិរីសោភក្នុងខេត្តត្រៃវែង -ស្រុកពាមជ្រៃ
ព្រះមហា ទុក - ផាន់ វត្តស្វាយជ្រុំក្នុងខេត្តស្វាយរៀង - ស្រុកស្វាយរៀង
ព្រះមហា ម៉ាន់ - ភេត វត្តស្វាយតាយ៉ានក្នុងខេត្តស្វាយរៀង - ស្រុក
ស្វាយចាប
លោក ផ្ដ - ហាយ វត្តពោធិអម្ពវ៉ែនក្នុងខេត្តកំពង់ចាម - ស្រុកចំការលើ
ព្រះមហា ម៉ុយ-សារ៉ា វត្តជ្រោតនាពមក្នុងខេត្តកំពង់ចាម -ស្រុកកំពង់សៀម
ព្រះមហា ម៉ែន - តាក់ វត្តពាមមង្គល ក្នុងខេត្តកណ្ដាល - ស្រុកមុខកំពូល
ព្រះមហា ពេជ - ផុល វត្តនិពោធរង្សីក្នុងខេត្តកណ្ដាល - ស្រុកកៀនស្វាយ

លោក នួច -ជី វត្តព្រៃពេង ក្នុងខេត្តកណ្ដាល ស្រុកកណ្ដាលស្ទឹង

ព្រះមហា ប្រាក់-សន វត្តកុលម្ពវ័ន ក្នុងខេត្តកំពង់ឆ្នាំង -ស្រុកកំពង់-ត្រឡាច

ព្រះមហា ទឹម-យៀវ វត្តវិហារហ្លួង ក្នុងខេត្តកំពង់ឆ្នាំង ស្រុករលាប្អៀរ

លោក សួង- សារិទ្ធ វត្តគិរីទេក្ខុណារាម ក្នុង ខេត្តតាកែវ ស្រុកព្រៃកប្បាស

លោក អ៊ុក -គូរ វត្តពោធិមណ្ឌល ក្នុងខេត្តតាកែវ ស្រុកត្រាំង

ព្រះមហា អ៊ូ -គុន វត្តតាំងគោក ក្នុងខេត្តកំពង់ធំ ស្រុកបារាយណ៍

ព្រះមហា គុយ ហ៊ាន វត្តកំពង់ធំ ក្នុងខេត្តកំពង់ធំ ស្រុកកំពង់ស្វាយ

លោក ចាន់ -វ៉ន វត្តរលាំងគ្រើល ក្នុងខេត្តកំពង់ស្ពឺ ស្រុកសំរោងទង

ព្រះមហា ឯក -អេង វត្តអង្គពន្ធី ក្នុងខេត្តកំពត ស្រុកអង្គរជ័យ

ព្រះមហា មាស - តាំម្ង វត្តបុព្វទិសារាម ក្នុងខេត្តសៀមរាប ស្រុកជីក្រែង

ព្រះមហា សំរិទ្ធិ បូរ វត្តយាកាប ក្នុងខេត្តពោធិសាត់ ស្រុកក្រគរ

ព្រះមហា ជា - សាយ វត្តបទុមវង្ស ក្នុងខេត្តក្រចេះ ស្រុកក្រចេះ

លោក ទន់ - ឈុន វត្តគតិញ្ញារាម ក្នុងខេត្តស្ទឹងត្រែង ស្រុកស្ទឹងត្រែង

លោក ចាន់ សុផាវិទ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

លោក គឹម -ចាប វត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ

លោក ស៊ាង -សារិទ្ធ វត្តស្វាយពពែ ក្រុងភ្នំពេញ

សេចក្ត៌កែតម្រូវ

អត្ថបទស្តីអំពី វត្តព្រះពុទ្ធសាសនានៅ ទត្តមាត់ជ្រូក កម្ពុជាក្រោម មានការយ្រៀងយ្ងាតពាក្យសំដីទ្ងះ សូមមេត្តាកែតម្រូវមុនទឹងអាន ជូចទាងក្រោមនេះ

ពាក្យទុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ឃុំទ្រីតុង	(ទ្រីតុង)	៥៣៩	១៥
លឹម	អឹម	៥៣៨	៣
ទម្ងាក់ស្ងាប់	ទម្ងាក់ចុះ	៥៨០	១៣
សង	សង់	៥៨២	១០
ស្រឡេង	ស្រឡូង	៥៨២	១៧
លៀងពី	លៀងកី	៥៨៣	៣-៥
វត្តស្ងាតាណិប	វត្តស្ងាយតាណិប	៥៨៣	៨
ភូមិថ្នាក់	ភូមិថ្ងាក	៥៨៣	១៣
សង្កែជួប	សង្កែជួច	៥៨៦	៦
ធៀបណាប	ធៀតណាប	,,	៦
ដើមផ្អៅប	ដើមផ្អៅក	,,	១៦
ធៀតណាម	ធៀតណាប	,,	

សន្ទឹកប្រាប់ពាក្យខុសត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ទិញត្រុង	ទិញទ្រុង	៥៨៥	១
អៀងគឺ	អៀងគឺ	"	១៣-១៤
វត្តវណងណង	វត្តវញ៉ងញ៉ង	៥៨៦	១
វ៉ាន់យ៉ាង	វ៉ាន់យ៉ាវ	"	៤-៥
នៅយុំ	នៅយុំញ៉ុងធឹង	"	៦
វត្តត្រស	វត្តត្រាស់	"	៧
ងឺន	ងឺន	"	៩